# សម្ភាសន៍ជាមួយឈ្មោះ ដួង សៀត ភេទប្រុស អាយុ៦២ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ “យោធា”

## ស្រុកកំណើតនៅភូមិថ្មី ឃុំថ្មី ស្រុកជ័យសែន ខេត្តព្រះវិហារ

## រស់នៅភូមិអូររំដួល ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

## ០១:៣៧:៥៨

## ៣៨ទំព័រ

វណ្ណៈ៖ ចឹងថ្ងៃហ្នឹងថ្ងៃទី២១ខែ១២ឆ្នាំ២០១៣ ហើយខ្ញុំឈ្មោះ សុខ វណ្ណៈ មកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំបានមកដល់ភូមិឃុំពីគឺចង់ដឹងរឿងរ៉ាវទាក់ទងនិងប្រវត្តិសាស្ត្រដែលយើងធ្លាប់ឆ្លងកាត់បីបួនជំនាន់មកហើយរហូតមកដល់ឥឡូវនេះ ចឹងបទសម្ភាសខ្ញុំជាពូហ្នឹង តើពូអាចឲ្យខ្ញុំយកទៅសរសេរជាសៀវភៅឲ្យក្មេងៗសិក្សាបានរៀនសូត្របានទេពូ ពូមិនថាអីទេ?

សៀតៈ ខ្ញុំមិនថាអីទេ បើនិយាយពីកិរិតយុត្តិធម៌វិជ្ជាអីបិតនៅក្នុងថ្នាក់អក្ខរកម្មដែរ ខ្ញុំវាមិនសូវចេះនិយាយអី ខ្ញុំនិយាយរឿងពិតជាក់ស្តែង សួរអីខ្ញុំឆ្លើយនោះ។

វណ្ណៈ៖ បាទ!អរគុណពូ។

សៀតៈ បាទ!បើឲ្យខ្ញុំផ្តើមផ្តួចខ្លួនខ្ញុំអត់ចេះដែលណា។

វណ្ណៈ៖ បាទ។

សៀតៈ ខ្ញុំប្រាប់ឲ្យត្រង់ខ្ញុំរៀនអក្ខរកម្មតាមព្រៃនោះ ពេលធំដឹងក្តីហើយគេហៅចូលព្រៃ ដើរព្រៃជាមួយគេ ចឹងរៀនអក្ខរកម្មទេ ដែលខ្ញុំចេះមើលអក្សររាល់ថ្ងៃខ្ញុំរៀនអក្ខរកម្មទេ រៀននៅក្នុងព្រៃទេ។

វណ្ណៈ៖ ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ ពូឈ្មោះអីដែរ?

សៀតៈ ខ្ញុំឈ្មោះ ដួង សៀត។

វណ្ណៈ៖ មានឈ្មោះហៅក្រៅទេពូ?

សៀតៈ អត់មានទេ។

វណ្ណៈ៖ អាយុប៉ុន្មានហើយរាល់ថ្ងៃ?

សៀតៈ ខ្ញុំអាយុ៦១ហើយជិត៦២ហើយ។

វណ្ណៈ៖ ប្រពន្ធពូឈ្មោះអីដែរ?

សឿតៈ  សៅ វ៉ន ។

វណ្ណៈៈ  គាត់អាយុប្រហែលជាប៉ុន្មានដែរ?

សឿតៈ  មើលឆ្នាំរកា ខ្ញុំម្សាញ់ប្រពន្ធរកា មិនដឹងជាប៉ុន្មានខ្ញុំមិនដឹង ប្រហែលជា៥៨ ។

វណ្ណៈៈ  អត់អីទេ ចឹងសព្វថ្ងៃពូប្រកបមុខរបរអីដែរ?

សឿតៈ  ខ្ញុំធ្វើស្រែចម្ការ ដាំដំឡូងអីហ្នឹង ។

វណ្ណៈៈ  មានធ្វើជាទាហានយោធាអីទេ?

សឿតៈ  អត់ទេ ខ្ញុំមុនមិញខ្ញុំធ្វើក្រុមប្រឹក្សាបានពីរអណត្តិដែរ ។

វណ្ណៈៈ  ចឹងឥឡូវឈប់ហើយ?

សឿតៈ  បាទៗ!អណត្តិទី៣នេះ ខ្ញុំសុំអភិបាលសម្រាក វាងងឹតភ្នែកជងជិះម៉ូតូទៅឆ្ងាយមិនបាន ទៅដល់ខេត្តឧត្តរមានជ័យខ្ញុំជិះម្នាក់ឯងមិនរួចទេ ។

វណ្ណៈៈ  ចឹងកូនចៅពូរាល់ថ្ងៃមានប៉ុន្មាននាក់ដែរ?

សឿតៈ  មានបួននាក់ប្រុសពីរស្រីពីរ ។

វណ្ណៈៈ  ចឹងកូនពូបួននាក់ហ្នឹងមានរៀបចំគ្រួសារហើយទាំងអស់ឬមួយនៅទេ?

សឿតៈ  បាំកូនខ្ញុំអាទី១នោះនៅជាប់រាល់ថ្ងៃទេ ទី២នោះគេបែកគ្នាគេលះលែងគ្នាមានកូនមួយ អាទី៣នេះការហើយនេះគេបែកគ្នាទៀតនោះ ចឹងដូចជានៅក្នុងបន្ទុកខ្ញុំដដែលទេ នៅបីនាក់ដដែលទេរាល់ថ្ងៃហ្នឹង ។

វណ្ណៈៈ  ចឹងម្នាក់ទៀតនោះបួន?

សឿតៈ  ម្នាក់ទៀតនោះគេនៅប្រពន្ធកូនគេ តែបីនាក់នេះនៅក្នុងបន្ទុកខ្ញុំដដែលទេ ។

វណ្ណៈៈ  ចឹងមិនទាន់បែកផ្ទះទេ ដោយសារមានបញ្ហាគ្រួសារ?

សឿតៈ  បាទ!នៅក្នុងបន្ទុកខ្ញុំដដែល ។

វណ្ណៈៈ  ចឹងស្រុកកំណើតពូវិញនៅភូមិអី?

សឿតៈ  មុនមិញគេឈ្មោះភូមិថ្មី តែក្រោយសម័យ ប៉ុល ពត គេដាក់ឈ្មោះភូមិតស៊ូ ដល់ឥឡូវគេហៅតស៊ូរាល់ថ្ងៃហ្នឹង ។

វណ្ណៈៈ  ខ្ញុំចឹងសួរពីកន្លែងកំណើតកន្លែងកើត?

សឿតៈ  ហ្នឹងហើយ ។

វណ្ណៈៈ  ឥឡូវភូមិថ្មី?

សឿតៈ  ឥឡូវដាក់តាមគេក៏បានដែរ ដាក់ភូមិតស៊ូទៅ ពីមុនភូមិថ្មី ឃុំថ្មី ស្រុកជ័យសែន ខេត្តព្រះវិហារ ។

វណ្ណៈ  ចឹងដាក់ភូមិថ្មីពីដើមទៅណាស់?

សឿត: បាទ!តែប្រវត្តិរូបខ្ញុំដាក់នៅដដែលភូមិថ្មី ឃុំថ្មី។

វណ្ណៈ  ចឹងស្រុកជ័យសែន?

សឿត: បាទ!ស្រុកជ័យសែន ខេត្តព្រះវិហារ។

វណ្ណៈ  ជ័យសែន ហ្នឹងមានឈ្មោះតាំងពីយូរមក?

សឿត: យូរហើយ តាំងពីជំនាន់សម្តេចតាយើង។

វណ្ណៈ  ចឹងភូមិដែលពូនៅរាល់ថ្ងៃនេះគេហៅភូមិអីវិញ?

សឿត: ភូមិរំដួល ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។

វណ្ណៈ  ចឹងពូមានឪពុកឈ្មោះអីដែរ?

សឿត: ឪពុកខ្ញុំឈ្មោះ យន់ តែត្រកូលគាត់ខ្ញុំមិនបានដឹងដែរ ដួង ចឹងដឹង ដួង យន់ ចឹងឯងបើខ្ញុំយកត្រកូលខ្ញុំដាក់ ដួង ហើយ។

វណ្ណៈ  ចឹងម្តាយ?

សឿត: ម្តាយខ្ញុំឈ្មោះ ស្រី ពាង។

វណ្ណៈ  ចឹងលោកទាំងពីរសព្វថ្ងៃគាត់ស្លាប់ហើយឬយ៉ាងម៉េច?

សឿត: គាត់ស្លាប់អស់ហើយ។

វណ្ណៈ  គាត់ស្លាប់តាំងពីសម័យណាទៅ?

សឿត: ឪពុកខ្ញុំស្លាប់ឆ្នាំ១៩៩៣ ម្តាយខ្ញុំស្លាប់ឆ្នាំ២០១២។

វណ្ណៈ  ចឹងគាត់ទើបស្លាប់ឥឡូវហ្នឹងដែរ?

សឿត: បាទ!ខ្ញុំមិនបានដឹងរឿងផង បងប្អូនខ្ញុំមិនបានចុចប្រាប់ខ្ញុំផង ខំយកលុយកាក់ទៅសន្ទានឲ្យម្តាយនៅស្រុកនោះ គេថាឯងក៏ក្រមកម្ងេះ ម្តាយឯងស្លាប់បាត់ហើយឯងមកធ្វើអី ចុះអត់មានប្រាប់ខ្ញុំផង ទៅដល់បានត្រឹមធ្វើបុណ្យបណ្តោយ អត់មានដឹងរឿង ព្រោះប្អូនវាអត់ប្រាប់នោះ។

វណ្ណៈ  ចុះមកបងប្អូនបង្កើតមានប៉ុន្មាននាក់?

សឿត: បងប្អូនបង្កើតដូចខ្ញុំថាមិញមានបួននាក់ហ្នឹង។

វណ្ណៈ  មិញកូនតើ?

សឿត: មើលបងប្អូនបង្កើត បងស្រីទី១គាត់ស្លាប់ហើយ។

វណ្ណៈ  ឈ្មោះអី?

សឿត: ដួង ឈួន ទី២ ដួង ភន បងខ្ញុំអាចនៅទួលស្លែងជាមួយគេហ្នឹងឯង។

វណ្ណៈ៖ គេចាប់ទៅទួលស្លែង ភន ហ៊ឹង?

សឿត៖ បាទ!ហ៊ឹងហើយបងខ្ញុំ ខ្ញុំទៅមើលទួលស្លែងខ្ញុំវង្វេងមុខបងខ្ញុំដែរ លេងចាំមុខបងប្អូននៅតូចពេកណាស់ ខ្ញុំជឿថាបងខ្ញុំនៅនោះឯង ។

វណ្ណៈ៖ ចឹងកាលសម័យហ្នឹងគាត់ធ្វើចលនាតស៊ូដែរ?

សឿត៖ តស៊ូជំនាន់នោះគាត់ទៅជាមួយវៀតណាម ដំបូងវៀតណាមមិនចូលមក ។

វណ្ណៈ៖ បាទ ។

សឿត៖ ចឹងកាលហ្នឹងបងខ្ញុំទៅជាមួយវៀតណាមចឹង កាលនោះគាត់ឈរជើងនៅកំពង់ចាមយើងនេះ ឆ្នាំ១៩៧២ ។

វណ្ណៈ៖ ចឹងគាត់ធ្វើធំដែរ?

សឿត៖ អត់ដឹងដែរ ក្រោយមកខ្ញុំសួរបងឯងនៅណា កាលហ្នឹងនិរសាគេរត់សំបុត្រមកនេះណាស់ ខ្ញុំសួរបងឯងនៅណា គាត់ថាអញនៅខេត្តកំពង់ចាមនេះឯង គាត់ថានៅក្រេកក្រេកចេះមិនជាបើមិនធ្វើជាយោធាអីហ្នឹងគេ ខ្ញុំថាបងខ្ញុំចង់ធ្វើដែលតើកាលហ្នឹង បងឯងយកខ្ញុំទៅបានអត់ ចាំមើលអញសួរអង្គការសិន ។

វណ្ណៈ៖ បាទ ។

សឿត៖ ដល់ថ្ងៃរំដោះថ្ងៃទី១៧មេសានេះ ឃើញកូនឡានតូចមួយគេមកគេសុំរូបថតឪពុកម្តាយកូនមានការផ្សាររចាំបាច់មិនអាចមកលេងបានទេ ខ្ញុំចាប់អារម្មណ៍ថាអាចចង់ឃើញឪពុកម្តាយបងប្អូនដែលណា ខ្ញុំពិចារណាថ្ងៃដែលខ្ញុំទៅជាមួយលោក សៅ ផាន អភិបាលរងនេះខ្ញុំស្តាយខ្ញុំអត់បានសួរអ៊ឹ ជុំ មី ដែលគាត់នៅនោះ លោគាត់ស្គាល់ ។

វណ្ណៈ៖ បាទ ។

សឿត៖ ជំនាន់នោះឯង ខ្ញុំដើរមើលកន្លែងគេធ្វើទារុណកម្មខ្ញុំស្រក់ទឹកភ្នែក គេបិទរូបថតគេដាក់ឈ្មោះអីខ្ញុំរកមើលឈ្មោះបងខ្ញុំវាមិនឃើញ ដោយសារឡានគេ គេទៅតែមួយថ្ងៃអត់មាននៅយូរណា គេថាឡានចេញទៅនេះទៅណានោះ មកកន្លែងសាលាក្តីនោះក៏ខានបានមើលទៅខ្ញុំដើររកមើលវាវង្វេងមុខបងខ្ញុំមិនដឹងម៉េចទេ ។

វណ្ណៈ៖ បើសិនជាយើងឃើញឈ្មោះ?

សឿត៖ បើយើងឈ្មោះយើងដឹង តែឃើញតែរូបថតលែងចាំមុខបងឯង ។

វណ្ណៈ៖ ចឹង ភន ហ្នឹងគាត់មានឈ្មោះហៅក្រៅទៀតទេ?

សឿត៖ ចាំមើលណាស់ ឈ្មោះ កំណើតគាត់ ដួង ភន ក្រោយមកគេឈ្មោះ យ៉ន គ្នាគាត់ហៅ យ៉ន មាឌគាត់ធំក្រអាញ ។

វណ្ណៈ ហ្នឹងបងទី២?

សឿតៈ បាទ ។

វណ្ណៈ ចឹងបងទី៣ឈ្មោះអីដែរ?

សឿតៈ ទី៣ខ្ញុំហ្នឹងហើយ ។

វណ្ណៈ ទី៤?

សឿតៈ ប្អូនស្រីខ្ញុំឈ្មោះ ដួង ឈា នៅទីតែពីរនាក់ទេ រាល់ថ្ងៃ ។

វណ្ណៈ ចឹងមានតែប្អូននាក់ដែរ?

សឿតៈ បាទ! តែប្អូនដូចកូនខ្ញុំដូចគ្នា ។

វណ្ណៈ ចឹងកាលពីតូចដំនាន់សីហនុអីពូមានបានចូលសាលារៀនទេ?

សឿតៈ កាលនោះខ្ញុំនៅចុងកាត់មាត់ញកជនបទផុតលេខបណ្ដោយ មានរោងដោលតូចមួយខ្ញុំទៅរៀនបានប៉ុន្មានខែ ដល់ខែគ្រូរាំកងហើយ មានគ្រូឡើងមកថ្មី គ្រូឡើងមកបីដល់នេះពួកគេទៅចូលសាលាមុនខ្ញុំគេគ្រូនេះដល់ហើយណា សៀវភៅកុមារដ្ឋានមូលណែនវាយសុទ្ធតែក្បាល សរសេរខុសវាយ ក៏ខ្ញុំខ្លាចខ្ញុំលែងទៅ អញអត់ទៅទេ គេហៅអានរាល់ថ្ងៃអញអត់ទៅទេ មិនទាន់បានប៉ុន្មានខែផងកើតរដ្ឋប្រហារក្ដួចប់ ខ្ញុំរៀនស្រះ«អ» ស្រះ«អា» មិនទាន់ចប់ផងហ្នឹង ។

វណ្ណៈ ប៉ុន្តែឥឡូវឃើញពូមើលអក្សរបាន?

សឿតៈ ឥឡូវខ្ញុំមើលបានតែខ្ញុំសរសេរមិនត្រូវអក្ខរាវិរុទ្ធអស់ទេ ខ្ញុំមើលបានទាំងអស់ ។

វណ្ណៈ ចឹងកាលហ្នឹងរៀនបាននៅក្នុងព្រៃវិញ?

សឿតៈ បាទ! ចឹងបានខ្ញុំថាឋិតនៅក្នុងអក្ខរកម្មទេ ចឹងបានខ្ញុំមិនភ្លេចគុណបងថ្លៃខ្ញុំទេ គាត់បង្រៀនខ្ញុំមុនខ្ញុំលះបង់ចូលព្រៃគាត់ថា ឯងចង់ចេះអក្សរទេ ខ្ញុំថាចង់ណាស់បងគេច្រៀងគេសរសេរអីក្នុងសៀវភៅទៅច្រៀងអីបាន ឯងភ្នែកខ្វាក់បានខំប្រឹង គាត់បាន«ក-ខ ស្រះអស្រះអាចប់» ហើយខ្ញុំមកសិក្សានៅក្នុងព្រៃរៀនតាមម្ចប់ឈើអី ចេះចង់ចាំខ្លួនឯង ។

វណ្ណៈ ចឹងកើតរដ្ឋប្រហារនៅឆ្នាំ១៩៧០ហ្នឹង ពូអត់មានបានរៀនទេ?

សឿតៈ មកដល់ឆ្នាំ១៩៧០ហើយលែងមានសាលាហើយ ជំនាន់នោះ លែងមានសាលាហើយ បើសាលា សាលាខ្មែរក្រហមគេរំដោះហើយនេះក្មេងបានថ្នាក់ទី៣គេយកទៅលើកទំនប់ប្រឡាយហើយ ។

វណ្ណៈ ចឹងពេលកើតមានរដ្ឋប្រហារឆ្នាំ១៩៧០ហើយ នៅកន្លែងភូមិស្រុករបស់ពូហ្នឹងមានរឿងអីកើតឡើង មានចលនា មានការអូសទាញ មានស្ដាប់ការអំពាវនាវទេ?

សឿតៈ អត់មានទេ នៅក្រោមការគៀបសង្កត់របស់កម្ពុជាប្រជាធិបតេយ្យ អត់មានពីណាមកទេ ។

វណ្ណៈ៖ ចឹងមានន័យថានៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យនៅខាងព្រះវិហារហ្នឹងចូលមកយូរ ហើយចឹងខាងទាហានលន់ នល់ ចូលមកអត់បានទេ?

សឿត៖ អត់បានទេ លន់ នល់ នៅបានតែនៅក្នុងទីក្រុងទេ ខាងនេះរំដោះតាំងពី៧០ហ្នឹងឯង គ្រាន់វាយព្រឹងឡើងមកតាមនេះអត់មានច្បាំងជាមួយពីណាទេ មានច្បាំងនៅខាងខេត្តព្រះវិហារនិងប្រាសាទព្រះវិហារទេ ។

វណ្ណៈ៖ ចឹងពេលរដ្ឋប្រហារហើយហ្នឹងនៅខាងព្រះវិហារហ្នឹងមានការទម្លាក់គ្រាប់បែកទេ?

សឿត៖ បាទ!មានទម្លាក់គ្រាប់បែកឆ្នាំ១៩៧២អាមេរិចកាំងធ្វើសកម្មភាពហើយ ។

វណ្ណៈ៖ ចឹងមានគ្រោះថ្នាក់ប្រជាជនទេ?

សឿត៖ មានអាបេ៥២ចាក់រណ្ដៅនៅមានសព្វថ្ងៃនេះ ។

វណ្ណៈ៖ ចឹងកាលហ្នឹងមានយុទ្ធជនចេញទៅធ្វើចលនាតស៊ូចូលព្រៃច្រើនគ្នាទេ?

សឿត៖ ចូលចុះកាលហ្នឹងធ្វើចលនាតស៊ូប្រឆាំងជាមួយចក្រព័តកាលហ្នឹង កាលហ្នឹងគេមិនហៅចក្រព័តពេលហ្នឹង ។

វណ្ណៈ៖ បាទ!ត្រូវហើយ ។

សឿត៖ គេហៅចក្រព័តអាមេរិចកាំង ទាំងគេទាំងខ្ញុំគេឃោសនាមកចេះតែទៅតាមគេតាមឯងទៅ ។

វណ្ណៈ៖ កាលហ្នឹងពីណាឃោសនា?

សឿត៖ អង្គការគេ ។

វណ្ណៈ៖ ចឹងមានដែលឮសម្ដេចធ្វើការឃោសនាទេ មានដែលឮទេ?

សឿត៖ បាទ!ហ្នឹងហើយសម្ដេចតាយើងឲ្យចូលព្រៃម៉ាគី ។

វណ្ណៈ៖ ឆ្នាំណាដែលពូបានចូលព្រៃម៉ាគីហ្នឹង?

សឿត៖ ខ្ញុំឆ្នាំ១៩៧៣ ខ្ញុំចូលក្រោយបងខ្ញុំ បងខ្ញុំចូលតាំងពីឆ្នាំ១៩៧០ គាត់ទៅជាមួយវៀតណាមដែលខ្ញុំថាមិញហ្នឹង បងខ្ញុំបាត់ខ្លួន ។

វណ្ណៈ៖ ចឹងកាលឆ្នាំ១៩៧៣ហ្នឹងទៅទេអត់មានគេមកអូសទៅទេ?

សឿត៖ អត់ទេ ខ្ញុំស្ម័គ្រចិត្តទៅខ្លួនឯង ។

វណ្ណៈ៖ ចឹងអ្នកនាំពូចូល ពូស្គាល់ទេ?

សឿត៖ អ្នកនាំខ្ញុំចូលទៅនោះមេភូមិឈ្មោះ អ៊ី យ៉ុន ទេខ្ញុំភ្លេចត្រកូលគាត់ឈ្មោះ យ៉ុន ចេះឯងចៅហ្វាយស្រុកឈ្មោះ វ៉ន គណៈតំបន់ឈ្មោះ ហង្ស ។

វណ្ណៈ៖ គណៈស្រុកឈ្មោះ?

សឿត៖ ឈ្មោះ វ៉ន ខ្ញុំមិនបានចាំត្រកូលគាត់ទេ ។

វណ្ណៈ៖ គណៈតំបន់ឈ្មោះ?

សឿតៈ ឈ្មោះ ហង្ស ។

វណ្ណៈ៖ ស្អី ហង្ស?

សឿតៈ អត់ចាំត្រកូលគាត់ផង ឈ្មោះ ហង្ស កាលហ្នឹងជាគណៈតំបន់ ។

វណ្ណៈ៖ ចឹងកាលហ្នឹងគណៈភូមិភាគមានទេកាលហ្នឹង?

សឿតៈ អត់មានទេ នៅតំបន់ស្វយ័តនៅឡើយកាលនោះ ក្រោយមកបានគេបញ្ចូលមកខេត្តឧត្តរមានជ័យ ។

វណ្ណៈ៖ ចឹងកាលពូចូលនៅឆ្នាំ១៩៧៣ហ្នឹងពូចូលជាទ័ពតំបន់ឬទ័ពស្រុក?

សឿតៈ ទ័ពស្រុកខ្ញុំនៅទ័ពស្រុក ។

វណ្ណៈ៖ ចឹងយោធាស្រុក?

សឿតៈ បាទ ។

វណ្ណៈ៖ ស្រុកអីគេ?

សឿតៈ ស្រុកជ័យសែន ។

វណ្ណៈ៖ ពីណាប្រធានយោធាស្រុក?

សឿតៈ ប្រធានយោធាស្រុកមិនដឹងជាស្អី លឿនទេ ។

វណ្ណៈ៖ ចឹងឈ្មោះ លឿន?

សឿតៈ ឈ្មោះ លឿន ខ្ញុំមិនបានចាំត្រកូលគេ ។

វណ្ណៈ៖ ចឹងពូចូលជាយោធាស្រុកបានរយៈពេលប៉ុន្មានបានចេញទៅទ័ពតំបន់វាយជាមួយទាហាន លន់ នល់ អីយ៉ាងម៉េចទៀត?

សឿតៈ ខ្ញុំមិនដែលបានវាយនិងគេទេ ខ្ញុំចូលនៅទាហានស្រុកហ្នឹងរហូតទាល់គេរំដោះចប់សព្វគ្រប់ដល់ឆ្នាំ១៩៧៧បានគេបញ្ជូនមកទាហានភូមិភាគឧត្តរមានជ័យប្រចាំយាមមុំដាំក្បាលផ្លូវយើងនេះ ។

វណ្ណៈ៖ ចឹងកាលនៅយោធាស្រុកតាំងពីឆ្នាំ១៩៧៣-៧៥បែកហ្នឹងយោធាស្រុកមានតួនាទីធ្វើអីដែរពូ?

សឿតៈ ខ្ញុំបើមែនទែននិយាយទៅនៅជាអង្គរក្សការពារចៅហ្វាយស្រុកទេ គ្រាន់នាំសារអី កាលនោះមិនមានទូរស័ព្ទមិនមានគេអូដូចនេះទេ ប្រើរត់សាររត់អី ។

វណ្ណៈ៖ ចៅហ្វាយស្រុកឈ្មោះ វ៉ន ហ្នឹង?

សឿតៈ ទេ វ៉ន នោះគេដូរហើយខ្ញុំមកនៅអង្គរក្សគេនោះឈ្មោះ យឿន ។

វណ្ណៈ៖ ចឹងឈ្មោះ យឿន?

សឿត៖ បាទ! ឈ្មោះ រ៉ន គេដូរឲ្យទៅនៅស្រុកសៀមបូក ។

វណ្ណៈ៖ ចឹងនៅឆ្នាំ១៩៧៥ភ្នំពេញរំដោះហើយអស់ចឹង គេបញ្ជូនពូទៅខាងណាវិញទៅ?

សឿត៖ ខ្ញុំនៅក្នុងស្រុកនៅឡើយទេ អត់ទាន់ទៅណាទេ ។

វណ្ណៈ៖ ចឹងដល់ឆ្នាំ១៩៧៧បានគេផ្លាស់ពូ?

សឿត៖ បាទ! បានគេឲ្យមកនៅទ័ពភូមិភាគ នៅតាមព្រំដែន ការពារព្រំដែនថៃ ។

វណ្ណៈ៖ ទ័ពភូមិភាគអី?

សឿត៖ ក្រោយមកគេដាក់ភូមិភាគឧត្តរមានជ័យ យើងហ្នឹង គេបូកបញ្ចូលហ្នឹង កាលសម័យនោះជាតំបន់ស្វ័យ័តក្រោយមកគេបញ្ចូនភូមិភាគឧត្តរមានជ័យ ។

វណ្ណៈ៖ នៅកងពលប៉ុន្មាន?

សឿត៖ កងពល០១២-១៣ខ្ញុំភ្លេចបាត់ទៅណាស់ មេ ផាន បាននៅចាំកាលនោះ ។

វណ្ណៈ៖ ប្រធានកងពលពីណា?

សឿត៖ ឈ្មោះ ស៊ី ស៊ី រាល់ថ្ងៃគាត់នៅសហរដ្ឋអាមេរិចនោះ ។

វណ្ណៈ៖ ចឹងគាត់នៅអាមេរិច?

សឿត៖ គាត់នៅអាមេរិកព្រមេ ផាន គាត់និយាយ ។

វណ្ណៈ៖ ចឹងកាលនៅការពារព្រំដេនមានគ្នាច្រើនទេ?

សឿត៖ ច្រើន គ្រាន់កម្លាំងពួកខ្ញុំមាន៦០នាក់ តែខ្ញុំកាលនោះដូចជាជាប់ក្នុងព័ន្ធធានាគាដែលហើយពេលគេចាប់ចៅហ្វាយស្រុកចៅហ្វាយខេត្តអស់ទៅ ខ្លួនខ្ញុំការរៀបចំរបស់ខាងលើមកចុះខ្ញុំមកលុតដំនៅហ្នឹង នៅមន្ទីរគ្នាតកូនដាំក្បាន្តនេះអស់ប៉ុន្មានឆ្នាំគេឲ្យដើរចម្ងាយដីតែ១០០ម៉ែត្រទេខ្ញុំ ១០០ម៉ែត្របួនជ្រុង ។

វណ្ណៈ៖ ចឹងពូមកនៅភូមិភាគខេត្តឧត្តរមានជ័យ?

សឿត៖ បាទ ។

វណ្ណៈ៖ នៅឆ្នាំ១៩៧៧ហ្នឹង ពូធ្វើទ័ពការពារព្រំដែនថៃ?

សឿត៖ បាទ ។

វណ្ណៈ៖ តែគេចាប់ពូទៀត?

សឿត៖ គេអត់មានចងអីទេ គ្រាន់គេរឹតត្បៀតយើងមិនឲ្យយើងដើរឆ្ងាយផ្តាចគេឲ្យយើងដើរដីបានតែ១០០ម៉ែត្របួនជ្រុងទេ ។

វណ្ណៈ៖ ចឹងពូនិយាយថាគេចាប់មេហ្នឹងឈ្មោះអីខ្លះ នៅឆ្នាំ១៩៧៧ហ្នឹងគេចាប់មេឬចាប់នៅឆ្នាំណា?

សឿត៖ តា ហង្ស ឆ្នាំ១៩៧៧ហ្នឹង មេខេត្តណាស់ ចៅហ្វាយខេត្ត គណៈតំបន់ ចឹងបានគេស្រាវជ្រាវមកធ្លាក់មកកូនចៅតូចតាចគ្មានមិនបានដឹងអីពិបាកណាស់ គេចេះតែតាមដានគេសង្ស័យខ្លាចថាយើងចេះចុះ ។

វណ្ណៈ៖ ចឹងពេលចាប់ តាហង្ស ហើយដាក់ពីណាមកវិញ?

សឿត៖ អត់មានពីណាមកទៀត ខាងរដ្ឋាភិបាលមកព្រឹបតែម្តង ។

វណ្ណៈ៖ ចឹងកាលចាប់ ហង្ស ហើយមានចាប់ពីណាទៀត?

សឿត៖ ចាប់ តាហង្ស ចាប់ តាយាង រងតំបន់ ខ្ញុំចាំតែឈ្មោះត្រកូលមិនចាំ ។

វណ្ណៈ៖ ចឹងនៅក្នុងឆ្នាំ១៩៧៧ហ្នឹងពូមានដឹងថាមានការចាប់មនុស្សផ្លាស់ប្តូរច្រើនទេ?

សឿត៖ បាទ ។

វណ្ណៈ៖ ចឹងចាប់ច្រើនដែរ?

សឿត៖ បើនិយាយរឿងចាប់ ចាប់ច្រើនណាស់កាលហ្នឹង តាមភូមិតាមអីរត់ព្រោងព្រាត ។

វណ្ណៈ៖ ចឹងពូមានដែលឃើញគេចាប់ដោយផ្ទាល់ភ្នែកពូដែលទេ?

សឿត៖ ខ្ញុំមិនដែលបានឃើញទេ គ្រាន់តែដឹងហើយឃើញអ្នករត់ កូនស្រីនៅជាប់កងក្បានដែលខ្ញុំជាប់គុកហើយគ្នារត់មកវង្វេងព្រៃគ្នារត់មក កូនស្រីពីរនាក់ដេកក្នុងព្រៃមួយយប់ព្រឹកឡើងបានមកដល់កន្លែងពួកខ្ញុំនេះ ពួកអ្នកលត់ដីដូចគ្នា គេនាំគ្នាធ្វើស្រែប្រាំងនៅកំពីងពួយនេះ ស្រុកដាំកងក្បានរាល់ថ្ងៃនេះមករាយការណ៍ប្រាប់បងប្អូនចេះៗដល់នេះពួកទាហានខ្ញុំនេះវាឈឺចាប់អាខ្លះអួរដើមកចេញទៅបាតុកម្មបណ្តោយ ។

វណ្ណៈ៖ ចឹងហ៊ានប្រឆាំងនិងរបបនិងទៀត?

សឿត៖ បាទ! ប្រឆាំងបណ្តោយប្រឆាំងជាមួយគេភ្លាមប្រត្តិកម្មដល់ប្រត្តិកម្មទៅ ទៅមិនរួចជាមួយគេចាប់បញ្ជូនទៅខេត្តឧត្តរមានជ័យអស់បាត់ខ្លួនបណ្តោយ ។

វណ្ណៈ៖ ចឹងកម្លាំងរបស់ពូហ្នឹងប្រឆាំង?

សឿត៖ បាទ ។

វណ្ណៈ៖ ចឹងយ៉ាងម៉េចពូបានជាគេមិនចាប់?

សឿត៖ ខ្ញុំដោយសារខ្ញុំមានគំនិតមួយ ខ្ញុំថាបើសិនថាមានខ្លាំងបង្កអុកឡុកមែនហេតុអីបានជាអង្គការមិនរៀបចំកម្លាំង ហើយពួកគេនោះគេដុះខ្លួនគេតែម្តង ដូចថាកម្លាំងឈឺចាប់ខ្លាំងពេកណាស់អត់មានពីណាបញ្ជាពីណាចាត់ចែងទេ ចឹងទៅខ្លួនឯង តែខ្ញុំរងចាំមើលគេបញ្ជា តើសកម្មភាពនេះវាយ៉ាងម៉េច ហើយគួរធ្វើយ៉ាងម៉េចគួរទប់ស្កាត់យ៉ាងម៉េច ដោយអត់មានឃើញពីណាបញ្ជាខ្ញុំសំងំនៅទៅ តែពួកគេនោះគេឈឺចាប់គ្រាន់ពូកូនស្រីគេមកគេអួលណែនដើមកគេ

និយាយលែងចង់ចេញទរណាយាត់ក៏មិនស្តាប់ដែរ សូម្បីមេវាវីរៈអីតាមព្រំដែនហាមយាត់អត់ស្តាប់ដែរ ទៅព្រោងព្រាតមានណា ដល់នេះគេធ្វើនយោបាយបាន គេហៅប្រមូលទៅដល់ខេត្តឧត្តរមានជ័យស្លាត់បាត់អស់រហូត ។

វណ្ណៈ មានច្រើនទេ កាលចាប់គ្នាទៅ?

សឿតៈ មាន៣៥នាក់ ។

វណ្ណៈ ចឹងកាលហ្នឹងកម្លាំងខ្មែរក្រហមដូចគ្នាងើបប្រឆាំងដែរ?

សឿតៈ ប្រឆាំង តែងើបមិនរួចដោយសារសម្ពាធគេងើបបាត់ខ្លួនៗ ។

វណ្ណៈ ចឹងចាប់ទៅខេត្តឧត្តរមានជ័យ?

សឿតៈ បាទ! ខេត្តឧត្តរមានជ័យ ។

វណ្ណៈ ចឹងមានគុកទេ នៅខេត្តឧត្តរមានជ័យរយៈពេលបីឆ្នាំហ្នឹង?

សឿតៈ ខ្ញុំអត់ដឹងដែរ ដឹងតែគេយកទៅនោះ បែបមានហើយបានជាគេយកទៅនោះ ។

វណ្ណៈ ចឹងកាលហ្នឹងគេមិនទុកចិត្តពូ ហើយគេចាប់ពូយកទៅដាក់ណាដែរឬនៅកន្លែងហ្នឹងដដែលឬមិនឲ្យដើរទៅណាយ៉ាងម៉េចពូ?

សឿតៈ ខ្ញុំនេះ ចាំមើលកាលដែលខ្ញុំចេញពីស្រុកមក៧/៧មកគឺថា គេឲ្យចូលបំពេញកងគេដកកម្លាំងមួយចំនួនទៅឧត្តរមានជ័យណាស់ ទៅណាៗគេឡើងទៅមេអី ហើយគេយកមកបំពេញដល់ក្រោយមកគេចាប់គណៈតំបន់ដូចខ្ញុំថាមិញ ឈ្មោះ ហុង នេះ គេចាប់ទៅគេស្រាវជ្រាវព្រោះកាលនោះដូចយើងរាល់ថ្ងៃដែរ មានស្អីណាអ្នកធ្វើការតាមថ្នាក់មកដល់នេះខ្ញុំមិនធ្វើការអីទេ តែខ្ញុំជាផ្នែកក្នុងមួយដូចសមាជិក ដូចថាជាគណៈបក្សប្រជាជនចឹងណាស់ ។

វណ្ណៈ បាទ ។

សឿតៈ កាលនោះគេថាដូចគ្នាដែរ គេសង្ស័យក្រែងលោយើងនេះមានគំនិតដូចមេដែរ មេបណ្តុះបណ្តាលអីយ៉ាងណាៗ អប់រំអីយ៉ាងណាៗគេដកសេចក្តីទុកចិត្តយើង ចឹងគេយកមកដាក់កន្លែងមុំ មកគេតាមដានគេត្រួតពិនិត្យមើល គេឲ្យដីយើងដើរ១០០ម៉ែត្របួនជ្រុង ។

វណ្ណៈ ចឹងពូមុនដំបូងពូនៅការពារខាងមុខទេ?

សឿតៈ បាទ ។

វណ្ណៈ ចឹងគេដកយកនៅមុំណាដាក់ភូមិអីឃុំអីដែរ?

សឿតៈ គេហៅមន្ទីរត្នាតកូន ភូមិដាំក្បាន្ត ស្រុកដាំក្បាន្តដែរ នៅរាល់ថ្ងៃជាកន្លែងកងពលធំនៅហ្នឹងនៅកន្លែងខ្ញុំចាស់ហ្នឹង ។

វណ្ណៈ មន្ទីរត្នាតកូន?

សឿតៈ ហ្នឹងហើយ ។

វណ្ណៈ ចឹងកន្លែងហ្នឹងមានសត្វត្មាតច្រើនបានគេហៅចឹង?

សឿតៈ មិនដឹងជាយ៉ាងម៉េចអ្នកស្រុកគេហៅចឹង ។

វណ្ណៈ ចឹងកាលពូនៅហ្នឹងមានឃើញសត្វត្មាតអីទេ?

សឿតៈ អត់ផង ។

វណ្ណៈ ចឹងមន្ទីរត្មាតកូនហ្នឹងជាមន្ទីរសន្តិសុខឬមួយជាកន្លែងស្អីមួយ?

សឿតៈ កន្លែងវរសេនាធំ ។

វណ្ណៈ វរសេនាធំលេខប៉ុន្មាន?

សឿតៈ វាភ្លេចហើយហ្នឹង ។

វណ្ណៈ ចឹងកាលហ្នឹងកងពលក៏ពូមិនបានដឹងដែរ?

សឿតៈ បាទ ។

វណ្ណៈ ចឹងកាលហ្នឹងប្រធានកងពលឈ្មោះអីដែរ?

សឿតៈ ឈ្មោះ ស៊ី តែគាត់រងគេទេ ប្រធានកងពលឈ្មោះ សឿន ។

វណ្ណៈ ចឹងសឿន?

សឿតៈ បាទ!គេហៅ សឿន សេះហោះ ក្រោយមកជំនាន់រដ្ឋាភិបាលវាយលុបមកនេះគាត់ក៏បាត់ខ្លួនទៅ ។

វណ្ណៈ សឿន រថក្រោះឬមួយសឿន សេះហោះ?

សឿតៈ គេហៅ សឿន សេះហោះ ព្រោះគាត់ច្រើនតែអួតប្រាប់ខ្ញុំថា ច្បាំងជំនាន់ លន់ នល់ គាត់ជិះសេះហោះ ជិះសេះបោកគ្រាប់បែកអីណាតាមគាត់និយាយខ្លួនគាត់ ចឹងពួកខ្ញុំហៅថា សឿន សេះហោះ ។

វណ្ណៈ ចឹងឥឡូវ សឿន សេះហោះនៅទេ?

សឿតៈ បាត់ខ្លួនតាំងពីយូរហើយតាំងពីឆ្នាំ៨២អីនោះ គាត់គឺងរីងពេកចឹង ដល់ហើយទាហានបាញ់នៅមិនបានគាត់រត់ចូលស្រុកថៃ តែឥឡូវមិនដឹងជានៅណាមិនដឹងជាគាត់ស្លាប់មិនជាគាត់រស់មិនដឹងដែរ ។

វណ្ណៈ ចឹងកាលហ្នឹងពូនៅកន្លែងអប់រំហ្នឹងដល់៧៩ឬក៏យ៉ាងម៉េចដែរ?

សឿតៈ បាទ!ដល់៧៩ ។

វណ្ណៈ ចឹងនៅកន្លែងអប់រំហ្នឹងមានគ្នាច្រើនទេ?

សឿតៈ បាទ!ជាប់១០០ជាងនាក់ ។

វណ្ណៈ   ១០០ជាងនាក់ហ្នឹង ត្រូវគេយកទោសម្ងាប់ហ្នឹងឬមួយនៅទាំងអស់?
សឿតៈ   ទេ មិនទាន់មានពីណាយកទៅសម្លាប់ទេ គេថាទោសមានវិន័យឲ្យធ្វើការងារធ្ងន់ៗកាប់គាស់ដី អីៗ
វណ្ណៈ   ចឹងឲ្យធ្វើចម្ការ?
សឿតៈ   បាទៗ
វណ្ណៈ   ចឹងពេលវៀតណាមចូលមកនៅឆ្នាំ១៩៧៩ចឹង ពូកាលហ្នឹងមិនបានរត់ទៅផ្ទះសំបែងវិញទេ?
សឿតៈ   អត់ទេ អត់រត់ទៅផ្ទះផងៗ
វណ្ណៈ   យ៉ាងម៉េចបានជាពូមិនរត់ទៅផ្ទះ?
សឿតៈ   ខ្លាច បើគេនិយាយថា វៀតណាមអាករ ហើយខ្ញុំកាលហ្នឹងវ៉ាយបុកឈុលមកចេះគេយកខ្ញុំទៅទុកនៅមាត់ទន្លេមេគង្គគេមិនបាននៅនេះទេ មេក៏រត់គាត់គាយខ្ញុំក៏រត់រហូតមកតាមហ្នឹងមក មកនៅជាមួយមេ ថាន រាល់ថ្ងៃហ្នឹងៗ
វណ្ណៈ   ចឹងពូរត់មកពីព្រះវិហារមក កាលហ្នឹងនៅព្រះវិហារហ្នឹងមានតាវឿន អីដែរ មេកងពលនោះកាលហ្នឹងពូមានស្គាល់ទេ?
សឿតៈ   តាវឿន ខ្ញុំអត់ស្គាល់ តាវឿនមកពីភូមិភាគឦសានៗ
វណ្ណៈ   ចឹងពូមានស្គាល់គាត់ទេ?
សឿតៈ   អត់ទេៗ
វណ្ណៈ   តែមានឮឈ្មោះគាត់ដែរទេ?
សឿតៈ   វឿន នៅណារាល់ថ្ងៃៗ
វណ្ណៈ   ឥឡូវប្រហែលជានៅខាងបន្ទាយឆ្មារ គាត់ជាប្រធានកងពលខាងខេត្តព្រះវិហារហ្នឹងដែរ កាលគាត់មកនៅឆ្នាំ៧៨អីហ្នឹងដែរ គាត់មកពេលមានការច្របូកច្របល់មានមនុស្សច្រើន ចឹងទៅមានការផ្លាស់ប្ដូរគាត់មកកាន់នៅហ្នឹង?
សឿតៈ   ខ្ញុំមិនដែលឮៗ
វណ្ណៈ   ចឹងតាសឿន សេះហោះហ្នឹងគាត់កាន់រហូតដល់ឆ្នាំ៧៩ហ្នឹងដែរ?
សឿតៈ   អត់ទេ អត់ដល់ អ!ពីមុនមកមិនដឹងជាគាត់នៅណាទេ ខ្ញុំទើបស្គាល់គ្នាពេលបែកបាក់គ្នាពេលនៅលើភ្នំហ្នឹងណាស់ នៅវីនសៃនៅជួបគ្នាបានតែប៉ុន្មានខែទេ ព្រោះកើតប្រត្តិការណ៍នោះក៏គាត់ភាសខ្លួនទៅណាបាត់ ពីមុនមិញគាត់នៅណាខ្ញុំមិនបានដឹងទេៗ
វណ្ណៈ   ចឹងពេលរត់ឆ្នាំ៧៩ហ្នឹងពូរត់ទៅដល់ណាទៅ?

សឿតៈ ខ្ញុំរត់ទៅដល់ខេត្តឧត្តរមានជ័យ យើង ខានលិចផ្លូវស្ទាច់យើងនេះឡើងមកវិញ មុំកូនក្រោលខ្ពុង កូន ថ្ម ទឹកជុំមកវិញរហូតទាល់ដាច់ខ្លួនបណ្តោយ ។

វណ្ណៈ កាលហ្នឹងរត់ជាអង្គភាពរត់ជាក្រុមរត់ទៅដល់ខេត្តឧត្តរមានជ័យស្ទាច់ទឹកជុំអីហ្នឹង កាលហ្នឹងរត់ទៅ ជួបពីណានៅហ្នឹងខ្លះ ជួបពីណាខ្លះដែលមានគំនិតបង្កកម្លាំងវាយជាមួយរដ្ឋាភិបាលជាមួយ ទាហានវៀតណាមអី ពូមានបានតស៊ូក្រោយឆ្នាំ៧៩ហ្នឹងដែលឬមួយអត់ទេ?

សឿតៈ កាលហ្នឹងតាសឿនហ្នឹងឯងនៅគ្រប់គ្រងហ្នឹង ។

វណ្ណៈ តាសឿន?

សឿតៈ តាសឿន ដែលខ្ញុំថាមិញហ្នឹង ។

វណ្ណៈ សឿន សេះហោះហ្នឹង?

សឿតៈ បាទ ។

វណ្ណៈ ចឹងពូនៅហ្នឹងស្គាល់ពីណាខ្លះទៅដល់ខេត្តឧត្តរមានជ័យស្ទាច់អីហ្នឹង នៅឆ្នាំ១៩៧៩ដដែលឬយ៉ាង ម៉េច?

សឿតៈ បាទ!៧៩ដដែល ។

វណ្ណៈ មានស្គាល់ពីណាខ្លះទេ កាលហ្នឹង?

សឿតៈ អត់មានស្គាល់ពីណាទេ ស្គាល់តែមេហ្នឹងដែលគេប្រាប់ថាបងសឿនៗ គេហៅទៅបើកអីវ៉ែអី វ៉ាន់មក មេៗគេទៅបើកយកមកចែកចែកចាយស្គាល់តែប៉ុណ្ណោះឯង ។

វណ្ណៈ ចឹងក្រោយ៧៩ហ្នឹងពូនៅខាងយោធាឬពូនៅខាងសំភារៈនៅខាងឃ្លាំងឬយ៉ាងម៉េចកាលហ្នឹង?

សឿតៈ អត់ទេ ក្រោយមកខ្ញុំនៅជាប្រជាជនធម្មតា គ្រួសារខ្ញុំសម្រាលកូនទៅក៏ឈឺច្រើនចឹងគេឲ្យខ្ញុំ ឈប់ ឲ្យខ្ញុំសម្រាកគេថាឯងនៅក្រោយទៅ នៅមើលប្រពន្ធកូន ចឹងទេមានហត្ថលេខាពីវរសេ នាតូចពីកងពលមក គេបញ្ជូនមកមេភូមិគេគ្រប់គ្រងទៅ ខ្ញុំក៏នៅភូមិហ្នឹងគេ ។

វណ្ណៈ នៅភូមិអីគេ?

សឿតៈ កាលនោះនៅភូមិលើភ្នំ មិនដឹងជាភូមិអីបើនៅស្រុកគេចឹង ។

វណ្ណៈ នៅស្រុកថៃ?

សឿតៈ បាទ!នៅត្រង់នេះបន្តិចត្រង់នោះបន្តិច ។

វណ្ណៈ ចឹងសឿន នៅក្រោយ៧៩គេមានបង្កើតកងពលថ្មីទៀតទេ?

សឿតៈ កងពលថ្មីទៀតមានពីណា មានតែ មាស មុត ហ្នឹងឯង ។

វណ្ណៈ ចឹងកងពលលេខប៉ុន្មាន មាស មុត?

សឿតៈ ខ្ញុំមិនបានដឹងលេខកងពល ។

វណ្ណៈ ចឹងដោយសារថាពូក្លាយជាប្រជាជនវិញហើយ?

សឿតៈ បាទ ។

វណ្ណៈ ចឹងក្រោយឆ្នាំ៧៩ហ្នឹងពូជាប្រជាជនវិញ?

សឿតៈ បាទ!ជាប្រជាជន ។

វណ្ណៈ ដោយសារពូមានប្រពន្ធកូន?

សឿតៈ ដោយសារកូនកើតមកវាមានជំងឺជាប់រហូត ចឹងមេឲ្យខ្ញុំសម្រាក ។

វណ្ណៈ មេឈ្មោះ សឿន ហ្នឹង?

សឿតៈ ទេ! មេនោះរត់ទៅបាត់ហើយ តែមេនេះមេវរតូចអនុសេនាធំ កងពលតូច ។

វណ្ណៈ ចឹងពេលពូនៅក្រោយ កម្លាំងនៅក្រោយហ្នឹងគេឲ្យពូធ្វើអីវិញពូ?

សឿតៈ កម្លាំងនៅក្រោយ គេត្រូវការស្បៀងអាហារគេប្រើយើងដឹកជញ្ជូនឲ្យគេ គេមកដាក់នៅចំណុចណាអីចំណុចណា រួចហើយយើងឡើងទៅវិញទៅ ។

វណ្ណៈ ចឹងកាលហ្នឹងគ្រាប់រំសេវឬមួយសម្ភារៈផ្សេងៗទៀតយើងបានមកពីប្រទេសណា?

សឿតៈ មិនដឹងជាយ៉ាម៉េចទេ តែពួគេថាមកពីប្រទេសចិន ។

វណ្ណៈ ចឹងអ្នកនៅខាងក្រោយមិននៅទំនេរ មិនវាយក្នុងសមរភូមិមែននៅខាងក្រោយគេឲ្យជួយជញ្ជូនគ្រាប់ដែរ?

សឿតៈ បាទ!ជួយជញ្ជូនយកទៅឲ្យគេដែរ ថ្ងៃណាគេត្រូវការគេហៅប្រើ ។

វណ្ណៈ ជញ្ជូនគ្រាប់ចុះមកខាងណាវិញ?

សឿតៈ ចុះមកមុខព្រះប្រឡាយយើងនេះ ។

វណ្ណៈ ចឹងពូមានបាននៅច្រក១០០១-១០០២-១០០៣ម្ដុំអស់ហ្នឹងទេ?

សឿតៈ នៅច្រក១០០៣បើ១០០២ខ្ញុំមិនបាននៅទេ ១០០១មិនបាននៅទេ នៅ១០០៣នៅខាងមុខនេះ ។

វណ្ណៈ ចឹងនៅព្រះប្រឡាយហ្នឹង?

សឿតៈ បាទ!ច្រកព្រះប្រឡាយហ្នឹង១០០៣ ។

វណ្ណៈ ១០០៣ហ្នឹងពីណាគ្រប់គ្រង?

សឿតៈ តាម៉ុក ។

វណ្ណៈ ពូស្គាល់តាម៉ុកច្បាស់ទេ?

សឿតៈ ស្គាល់តាម៉ុក នោះគាត់មិនចេះខ្លាចពីណាទេ មិនដូចមេៗខាងលើទេ គាត់ត្រូវការដើរអាណា មានម្ហូបអីធ្វើដាំធ្វើស្ងអី គាត់មកដួក់មកហូបជាមួយយើងហ្នឹង គាត់គ្មានខ្លាចពីណាបំពុលគាត់ទេ ដើរដេរប្រចោរពេញហ្នឹងហើយ ។

វណ្ណៈ គាត់ពូកែដេរ?

សឿតៈ បាទ!ពូកែដេរណាស់តាហ្នឹង ដេរប្រចោររួចហើយឲ្យម្ហូបឲ្យអាហារ ។

វណ្ណៈ ចឹងតាម៉ុកអត្តចរិកគាត់យ៉ាងម៉េចដែរ?

សឿតៈ តាម៉ុក អត្តចរិកគាត់ជាមនុស្សមិនចេះលាក់មាត់ ឃើញអីទាស់ត្រូវដេរៗទៅ តែក្រោយមកហៅយើងឲ្យទៅយកម្ហូបអាហារត្រីខ អំបិលប្រហុកប៊ីចេងអី បើឃើញស្ត្រីសួរថា ប្តីផែងទៅណា? ប្តីខ្ញុំទៅសមរភូមិមុខ អើទៅវាយយួនទៅកុំក្រឡេក្រឡចាំឲ្យច្បាស់ពួកផែង ចរិកចឹង ៦៨ ។

វណ្ណៈ ចឹងកាលចុះទៅវាយយួនវាយជាមួយកម្លាំងរដ្ឋាភិបាលកម្លាំងខ្មែរក្រហមកម្លាំងយួនអីងាប់ច្រើនទេ?

សឿតៈ ងាប់ច្រើន តាមទាហានគេនិយាយទេ ដូចខ្ញុំប្រាប់មិញថា ខ្ញុំគ្រាន់តែជាអ្នកដឹកជញ្ជូនឲ្យគេ គេថាងាប់ច្រើនណាស់ តាំងវៀតណាមតាំងខ្មែរងាប់ដូចតែគ្នាហ្នឹង ចុះ«បេអឹម»ស្រោចដូចស្អីហើយគេចយ៉ាងម៉េចផុតទៅដាក់ត្រង់ណាឆេះត្រង់នោះ ។

វណ្ណៈ ចឹងពូនៅកងដឹកជញ្ជូនចឹងមិនសូវមានគ្រោះថ្នាក់ប្តូមួយយ៉ាងម៉េច?

សឿតៈ មានខ្លះគ្រោះថ្នាក់ដែរ បើគេជម្លៀសទាន់មិនអី បើជម្លៀសមិនទាន់គេឡើងព័តហើយយើងមិនអាចដឹងទេ ផ្ទុះព្រើងយើងមានគ្រោះថ្នាក់ហើយ បើគេដឹងមុនគេជម្លៀសយើងមុនដែរ ឲ្យចេញឲ្យឆ្ងាយ មានទាហានគេការពារ ។

វណ្ណៈ ចឹងកាលហ្នឹងកម្លាំងខាងរដ្ឋាភិបាលបូកជាមួយកម្លាំងវៀតណាមហ្នឹង វាយខ្លាំងទាល់តែកម្លាំងខ្មែរក្រហមរត់ចូលដីថៃហ្នឹងនៅឆ្នាំណាដែរ ពូមានចាំទេ?

សឿតៈ ឆ្នាំ៩០ប៉ុន្មានទេ ។

វណ្ណៈ អត់ទេ អាហ្នឹងវាយក្រោយទៀតទេ អាហ្នឹងមិនមែនវាយជាមួយកម្លាំងវៀតណាមទេ អាហ្នឹងកម្លាំងរដ្ឋាភិបាលជាមួយកម្លាំងហ៊ុនស៊ីនប៊ុនអី ញ៉ឹក ប៊ុនឆៃ វាយឡើងភ្នំអាហ្នឹងក្រោយទៀតទេ តែគេថាមុនហ្នឹងមុនបោះឆ្នោត កាលវៀតណាមនៅសហការជាមួយទាហានរដ្ឋាភិបាល កម្លាំងកាលហ្នឹងខ្លាំងវាយសម្អាតរហូតដល់ភ្នំហើយបានចុះមកវិញ?

សឿតៈ អូ!ឆ្នាំ៧៩ហ្នឹង ៧៩-៨០ ។

វណ្ណៈ បើតាមដឹងថាឆ្នាំ១៩៨៥ វាយខ្លាំង?

សឿតៈ បាទ! បើថា៨៥-៨៦ខ្លាំងមែនហើយ ។

វណ្ណៈ ចឹងក្រោយមកទៀតវៀតណាមដកទៅវិញពូមានដឹងទេ ដកទៅស្រុកកំណើតគេវិញ ពូមាន ដឹងទេ?

សឿតៈ ដឹងដកពេលណា ។

វណ្ណៈ បើតាមឯកសារវៀតណាមដកទៅវិញឆ្នាំ៨៩?

សឿតៈ បាទ ។

វណ្ណៈ តែក្រោយមកទៀតនៅសល់ខ្មែរនិងខ្មែរវាយគ្នាបន្តទៀត មានតែកម្លាំងខាងរដ្ឋាភិបាលនិង កម្លាំងខ្មែរក្រហម ចឹងកម្លាំងខ្មែរនិងខ្មែរវាយគ្នានៅមានសកម្មភាពវាយគ្នាខ្លាំងដែរឬក៏មិនសូវ ខ្លាំងទេ?

សឿតៈ មិនសូវខ្លាំងប៉ុន្មានទេ វាយរបេះរបោះដែលទេ ពីព្រោះអីខ្មែរក្រហមគេផ្តាច់ជំនួយអស់ហើយ កាលហ្នឹង ។

វណ្ណៈ ពេលវៀតណាម?

សឿតៈ ហ្នឹងហើយគេផ្តាច់ជំនួយអស់ហើយ ខាងរដ្ឋាភិបាលត្រូវបានសកលលោកគាំទ្រ ខាងខ្មែរ ក្រហមគេផ្តាច់ជំនួយអស់ហើយ ចឹងទេមកឆ្លាចុះឆ្លាឡើងបានខ្ញុំថា បានផ្តាច់ខ្លួនមកចេះខ្ញុំអរដូច បានកើតម្តងទៀត បើសិននៅរាំរ៉ៃទាំងខ្ញុំទាំងគេប្រើទៅ ខ្ញុំមិនជាទាហានមែន តែបើគេបាញ់ គ្នាមិនត្រូវគ្រាប់ផាប់ដូចគ្នា គេផ្លោងមកត្រូវផាប់ដូចគ្នាហ្នឹង ចឹងទេ អស់ជើងអស់ដៃត្រឹមនេះ ឯង ។

វណ្ណៈ ចឹងកាលហ្នឹងពូនៅត្រឹមដឹកជញ្ជូនទេ បើសិនជាកងទ័ពតាមខ្ញុំធ្មើបទសម្ភាសទៅខ្លះចូលជិតដល់ ភ្នំពេញទៀត កម្លាំងចុះពីខាងហ្នឹងទៅ?

សឿតៈ ហ្នឹងហើយទាហានគេទៅជ្រៅណាស់ ។

វណ្ណៈ ចឹងដូចជាអាវុធអីមានជញ្ជូនទៅដល់ដែលឬមួយយ៉ាងម៉េច ឬមួយមានមធ្យោបាយទិញដូរ នៅខាងក្នុងឬមួយយ៉ាងម៉េច?

សឿតៈ អត់ទេ អត់មានទិញយកទៅពីលើ បើស្បៀងទិញនៅហ្នឹងមែន ។

វណ្ណៈ តែកម្លាំងខ្មែរក្រហមសម័យតស៊ូមានឲ្យប្រាក់ខែដែលទេ?

សឿតៈ គ្មានលុយណាមួយកាក់ ។

វណ្ណៈ ចឹងបានហូបចុកគ្រប់គ្រាន់?

សឿតៈ បាទ! អ្នកណាមិនធ្វើផ្តាច់របបទាំងប្តីទាំងប្រពន្ធ បើមិនធ្វើ ។

វណ្ណៈ ចឹងកាលនៅ១០០៣ហ្នឹង តាម៉ុក មានប្រាប់ឲ្យអ្នកនៅខាងក្រោយបិតចំរ៉ូងអីមានទេ?

សឿតៈ មានពួកខ្ញុំហ្នឹងហើយកម្ទាំងក្រោយ ប្រជាជនអ្នកបិតចំរ៉ូង ។

វណ្ណៈ ចឹងគេបិតរបៀបយ៉ាងម៉េចដែលពូអាចរៀបរាប់បានទេ គេយកអីមកបិត?

សឿតៈ គេយកឫស្សីយើងហ្នឹង ។

វណ្ណៈ ហើយគេកាត់ប្រវែងប៉ុន្មាន?

សឿតៈ តាមថ្នាំងវាថ្នាំងវែងថ្នាំងខ្លី ។

វណ្ណៈ ប្រវែងប្រហែលជាពីរទៅបីតឹកដែរ?

សឿតៈ បាទ!បីតឹក ។

វណ្ណៈ ចឹងគេបិតមានលក្ខណៈស្រួចចុងដើមឬមួយយ៉ាងម៉េច?

សឿតៈ ដូចរំពែងចុះបិត ប៊ិតៗយើងឆាកបន្តិចក៏មុតដែរ ។

វណ្ណៈ ចឹងចំរ៉ូងបិតបានយកទៅដាក់នៅសមរភូមិមុខហ្នឹងមានប្រសិទ្ធភាពទេ?

សឿតៈ គ្មានទេ ខ្ញុំនិយាយគ្មានប្រសិទ្ធភាពទេ ដាក់បេះគេដុតព្រៃឆេះអស់ខ្ទិចទៅ គេឃើញហើយគេដើរវាយរះក្រវ៉ែតខោលដួលអស់ទៅ ចុះយើងចាក់ក្នុងដីបេះវាមានទៅពូកែស្អី បើគេបាញ់ផាំងទៅបើយើងរត់វាអាចមុតបានណាស់ បើគេដើរឃើញគេយកដំបងវាយរះចោលអស់ ដួលអស់ ។

វណ្ណៈ ចឹងបើសិនជាយើងរត់មានគ្រោះថ្នាក់?

សឿតៈ បាទ!បើរត់ប្រជិតប្រជីងអាច ។

វណ្ណៈ ចឹងបើដើរលុករកទិសដៅអត់មានបញ្ហាទេ?

សឿតៈ អត់បញ្ហាទេ គេដឹងថាចំរ៉ូង យកដំបងវាយរះក្រវ៉ែតចោល ។

វណ្ណៈ តែនៅតែឲ្យប្រជាជនធ្វើ មិនឲ្យប្រជាជនទំនេទេ?

សឿតៈ បើគេប្រកាន់ថា មាគ៌ាគេសង្គ្រាមឈ្លប ។

វណ្ណៈ ចឹងនៅលើភ្នំហ្នឹងមានប្រជាជនច្រើនរយរាប់ពាន់នាក់ដែលទេ?

សឿតៈ រាប់សែននោះ ។

វណ្ណៈ ចឹងមានច្រើន?

សឿតៈ បាទ!មិនមែនតិចណា ។

វណ្ណៈ នៅលើភ្នំ១០០៣ហ្នឹងចំណុចហ្នឹងនៅចំព្រះប្រឡាយហ្នឹងដែរ?

សឿតៈ បាទ!ចំមុខហ្នឹង ។

វណ្ណៈ ចឹងនៅ១០០៣ហ្នឹងនៅក្នុងដីថៃឬមួយដីយើងទេ?

សឿតៈ កាលនោះតាម៉ុក គាត់ថាដីយើងតែឥឡូវថៃវាមកយកអស់ហើយ សូម្បីតែបន្ទាយយើងហ្នឹងវាមកជិតដល់ប៉ើយអស់ហើយ កាលមុនតាម៉ុក គាត់សង់ផ្ទះមួយជាបន្ទោលព្រំដែនឡាក់ដល់ក្រោយមកទៀតទៅទាហានថៃវាឡើងមកដល់លើហ្នឹងទៀត មកដល់ប៉ើយហ្នឹង ។

វណ្ណៈ ចឹងដោយសារពូរស់នៅក្នុងខេត្តព្រះវិហារជាស្រុកកំណើតរបស់ពូចឹង ខ្ញុំចង់ភ្ជាប់ទៅរឿងប្រាសាទបន្តិច កាលប្រាសាទព្រះវិហារយើងឈ្នះក្តីនៅឆ្នាំ១៩៦២ ថៃអត់មានបាននៅលើប្រាសាទទេ តែក្រោយៗមកមានសង្រ្គាមរហូតដល់សម័យខ្មែរក្រហមគ្រប់គ្រង ពូមានបានដឹងទេថា សម័យបីឆ្នាំហ្នឹងមានថៃមកឈរលើប្រាសាទបានទេ?

សឿតៈ អត់មានទេ ។

វណ្ណៈ ចឹងក្រោយ៧៩ទៀត សម័យតស៊ូអីហ្នឹង តើថៃមានមកនៅលើហ្នឹងដែរឬមួយកាលហ្នឹងមានតែទាហានខាងរដ្ឋាភិបាលកាលនោះ?

សឿតៈ កាលនោះចាំមើល ក្រោយពីរដ្ឋាភិបាលរំលំរបបកម្ពុជាប្រជាធិបតេយ្យហើយ ខាងរដ្ឋាភិបាលអ្នកគ្រប់គ្រង ក្រោយមកបានពួកទាហានកម្ពុជាប្រជាធិបតេយ្យវាយរំដោះដណ្តើមពីរដ្ឋាភិបាលវិញ ចឹងបានទាហានខ្មែរក្រហមកាន់កាប់រហូតទាល់ផ្តាច់ខ្លួនហ្នឹងតែម្តង ចឹងកាលហ្នឹងទាហានថៃអត់មានមកលាយឡំបានទេ ។

វណ្ណៈ ចឹងមានផ្ទះក្រហមមួយអ្នកខ្លះនិយាយថា តាម៉ុកធ្វើ ខ្លះនិយាយថា ថៃធ្វើដូចជាមិនច្បាស់?

សឿតៈ មិនមែនទេ ផ្ទះក្រហមហ្នឹងខាងថៃធ្វើមែន ថៃធ្វើនេះតាមខ្ញុំយល់ ថៃពិសោធន៍ពីតាម៉ុក ដូចខ្ញុំថានៅដុបរុននេះណាស់ តាម៉ុក ធ្វើដូចជាបន្ទោលឡាក់តែម្តង ឡាក់ព្រំហ្នឹង ដល់ថៃវាពិនិត្យពិចារណាមើលបានវាសាងសង់ផ្ទះក្រហមហ្នឹងទៅ អាចវាមានគំនិតមហិចតាលោភលន់យកប្រាសាទរបស់យើងនេះ ចឹងវាក៏សង់ពីខាងកើតប្រាសាទព្រះវិហារយើងនេះ យើងមើលពីប្រាសាទដណ្តើរ៦០ចឹងទៅយើងឃើញហើយ ។

វណ្ណៈ ចឹងផ្ទះក្រហមហ្នឹងបើថៃសង់នៅឆ្នាំណាដែលបើតាមពូដឹង?

សឿតៈ ប្រហែលជាឆ្នាំ៨៨-៨៩ មុនផ្តាច់ខ្លួនសាងសង់ ។

វណ្ណៈ ចឹងពូមានបានទៅមើលទៅដល់ផ្ទះក្រហមហ្នឹងដែលឬអត់?

សឿតៈ អត់ទេ ពួកខ្ញុំមិនដែលហ៊ានទៅទេ គេម៉េចអនុញ្ញាតឲ្យយើងទៅ យើងគ្រាន់មើលពីប្រាសាទយើងទៅ ថតស្រមើមើល ។

វណ្ណៈ ចឹងកន្លែងហ្នឹងថៃនៅយូរហើយកម្លាំងខ្មែរក្រហមអត់មាននៅហ្នឹងដែរ?

សឿតៈ អត់មានទេ គេនៅដីគេ យើងនៅដីយើង ។

វណ្ណៈ៖ តែមានផ្លូវចុះមកទៀតហ្នឹង គេថាផ្លូវហ្នឹងថៃទើបធ្វើថ្មីៗហ្នឹងទេ កាលហ្នឹងយើងត្រូវគ្នាឲ្យភ្ញៀវទេសចរណ៍ចេញចូលយកលុយយកអីហ្នឹង បានថៃធ្វើពីផ្ទះក្រហមចូលមកដល់ជើងប្រាសាទហ្នឹង?

សឿត៖ បាទ!ក្រោយមកខ្ញុំមិនដែលបានឃើញ ខ្ញុំអត់ដឹង នេះក្រោយមកទេ ស្រុកយើងកំពង់អភិវឌ្ឍន៍មិនដែលបានឃើញទៀតទេ ផ្លូវណាខ្លះខ្ញុំក៏មិនបានដឹងដែរ ផ្លូវមានច្រើនណាស់ ផ្លូវណាឡើងបុសស្បូវឡើងខាងណាៗ រដ្ឋាភិបាលធ្វើបានច្រើនណាស់ ខ្ញុំមិនដែលបានឃើញទេតាំងពីផ្តាច់ខ្លួនមករហូត ។

វណ្ណៈ៖ ចឹងខ្ញុំចង់សួរបកទៅ១០០៣វិញ ក្រោយមកឮថា តាម៉ុក គាត់បានធ្វើផ្លូវខ្វាត់ខ្វែងច្រើនចុះមកដល់ប្រាសាទព្រះវិហារ ពីអន្លង់វែងជាអី តាមផ្លូវជុបរុនអីចឹង តាម៉ុក គាត់ធ្វើហ្នឹងគាត់មានគំនិតយ៉ាងម៉េចដែរ បើតាមពូយល់?

សឿត៖ ខ្ញុំអត់យល់ដែរ គាត់ធ្វើហ្នឹងមិនដឹងជាគាត់ធ្វើយ៉ាងម៉េច គាត់ធ្វើសម្រាប់ចល័តដឹកទាហានដឹកគ្រាប់ដឹករំសេវឬគាត់ធ្វើសម្រាប់ដាក់ប្រជាពលរដ្ឋអីយ៉ាងម៉េច ព្រោះខ្ញុំអត់យល់ដែរ ។

វណ្ណៈ៖ ឬមួយគាត់ធ្វើកុំឲ្យថៃវាលុកមកទៀត ឲ្យដឹងថាផ្លូវរបស់យើងអីចឹង វាជាការទប់ស្កាត់មួយដែរឬមួយយ៉ាងម៉េច?

សឿត៖ ប្រហែលចឹងមិនដឹង ខ្ញុំអត់យល់ដែរ បើជំនាន់នោះនិយាយពីថៃវិញ បន្ទាយវានៅទល់មុខប្រាសាទនេះ វាបោះបង់ចោលហើយហ្នឹង វាមាននៅឯណាអត់ បន្ទាយទល់មុខប្រាសាទព្រះវិហារយើងហ្នឹង ជំនាន់នោះអត់មាននៅទេ វាដកចេញនៅណានោះ ក្រោយមកបានវាមកសាងសង់នៅវិញ មកបានសហការគ្នាជាប់ធ្វើការជាមួយគ្នា តែវាអត់មានមកលោភលន់លើប្រាសាទអីជាមួយយើងទេ ស្ពានទី១នៅក្រោមជណ្តើរ អានោះក៏នៅជាដីយើងដែរ តែឥឡូវវាកិលឡើងមក ឥឡូវខ្ញុំមិនដែលបានឃើញទៀត ។

វណ្ណៈ៖ ចឹងតាម៉ុក គាត់បានធ្វើផ្ទះមួយនៅចំព្រះប្រឡាយហ្នឹងឬមួយអត់ទេ?

សឿត៖ ចំជុបរុនយើងនេះ ។

វណ្ណៈ៖ ចឹងផ្ទះហ្នឹងមាននៅទេរាល់ថ្ងៃ?

សឿត៖ រុះអស់ហើយ រុះហើយបានថៃវារំកិល ។

វណ្ណៈ៖ ចឹងរំកិលមកដល់ផ្ទះហ្នឹងហើយ?

សឿត៖ រំកិលហួសទៀត ។

វណ្ណៈ៖ ចឹងហួសផ្ទះតាម៉ុក ធ្វើទៀត?

សឿត៖ បាទ!ហួសហើយ ។

វណ្ណៈ:  ចឹងតាម៉ុក ធ្វើនៅជុបរុនហ្នឹងគាត់ធ្វើនៅខាងក្រោមឬមួយធ្វើនៅលើភ្នំ?

សឿតៈ:  ធ្វើនៅលើភ្នំ ។

វណ្ណៈ:  តែផ្លូវលើភ្នំហ្នឹងមានទាហានយើងការពារដែលតើ?

សឿតៈ:  នៅតើ ។

វណ្ណៈ:  តែនៅមិនដល់ចំណុចតាម៉ុកធ្វើទេ?

សឿតៈ:  អត់ដល់ទេ នៅជិតប៉ើយនេះ ។

វណ្ណៈ:  ចឹងវាយកពីចំណុចតាម៉ុក ធ្វើផ្ទះហ្នឹងប្រហែលជាប៉ុន្មានទៀតបើតាមពូដឹង?

សឿតៈ:  ប្រហែលជា២០០ម៉ែត្រជាង ។

វណ្ណៈ:  ចឹងជិត២០០ច្រើនដែរ?

សឿតៈ:  បាទ!វាជិតដល់ប៉ើយហើយហ្នឹង ។

វណ្ណៈ:  ផ្លូវស្រុកយើងមានសន្តិភាពទៅថៃវាចេះតែរំកិលមក?

សឿតៈ:  បាទ! រំកិលហើយវាធ្វើថ្មីយកស្ដីចុចមកបុកដាច់ទល់មុខទំនប់ដាច់យើងនេះ អាប៉ើយយើងមើលទៅឃើញហ្នឹង មុនមិញមិនមែននៅហ្នឹងទេ ក្រោយនោះបន្ទាយវានៅក្រោយផ្ទះតាម៉ុកទៀតតាម៉ុកធ្វើនោះ តាម៉ុក ធ្វើនៅមុខនោះគាត់ដូចជាធ្វើព្រំឡាក់តែម្ដង ក្រោយមកទៀតវាមានពិសោធន៍វាមកធ្វើសង់វត្តទល់មុខទំនប់ដាច់នេះ សង់វិហារមួយជាប់នៅប៉ើយភ្នំហ្នឹង ។

វណ្ណៈ:  ចឹងយើងអត់មានហាមឃាត់ទេ?

សឿតៈ:  អត់ទេ ។

វណ្ណៈ:  វត្តថៃធ្វើនៅឆ្នាំណា?

សឿតៈ:  អាច១១២០០៣ ។

វណ្ណៈ:  យើងត្រូវគ្នាហើយហ្នឹង?

សឿតៈ:  បាទ!កាលហ្នឹងនៅទេ ។

វណ្ណៈ:  យើងមិនទាន់មានសមាហរណ៍កម្ម?

សឿតៈ:  នៅឡើយទេ ។

វណ្ណៈ:  ចឹងកាលហ្នឹងធ្វើមុនសមាហរណ៍កម្មទៀត?

សឿតៈ:  បាទ!ធ្វើមុនហើយ ដល់ពេលយើងវាយគ្នាចឹងទៅខាងរដ្ឋាភិបាលយកទ័ពបាញ់ចូលក្នុងវត្តនោះ វាចេះតែសរុបគ្រាប់មួយពីរបីបួន...ចឹងទៅទាហានវានៅនោះ ស្រួលវារាយការណ៍ឲ្យមេវាបាញ់ចូលទឹកដីវាណាណី តាមការពិតដីយើងវាមកនៅប្រាំងភ្នំចេះ ។

វណ្ណៈ:  ចឹងវត្តហ្នឹងមានលោកនៅទេរាល់ថ្ងៃហ្នឹង?

សឿតៈ អត់មានទេ គ្រាន់តែសាងសង់ដូចខ្ញុំថាមិញ ដូចវាធ្វើជាបង្គោលព្រំឡាក់មួយដើម្បីវាស្ទីន យើងចឹង ។

វណ្ណៈ ចឹងដូចជាវាធ្វើលយើង?

សឿតៈ បាទ!លមើលយើងរើមិនរើសអីយ៉ាងម៉េចនោះណាស់ វាសង់ស្ពានទេ មានលោកណានៅអត់ មុនមិញវាលាបថ្នាំក្រហមដល់ខាងរដ្ឋាភិបាលឃើញថ្នាំក្រហមច្បាស់ពេកទៅក្រោយមកវាយក ជាងមកឲ្យលាបថ្នាំពណ៌ដីវិញ ឥឡូវមើលពីទំនប់ដាច់លែងឃើញ មុនមើលឃើញក្រហមឆឹង ឥឡូវមើលលែងឃើញហើយលាបពណ៌ដី ។

វណ្ណៈ ចឹងនៅ១០០៣ហ្នឹងមានប្រជាជនរាប់សែននាក់ចឹង តើគាម៉ុកឲ្យមានសាលារៀន ឲ្យមានធ្វើស្រែចម្ការឬមួយយ៉ាងម៉េចដែរនៅ១០០៣ហ្នឹង?

សឿតៈ អត់ទេ បើនិយាយពីចម្ការស្រែគ្មានទេ បើអង្ករគេចឹញ្ចឹម ។

វណ្ណៈ ចឹងយើងបិតតែចំរូងទៅ?

សឿតៈ បាទ ។

វណ្ណៈ ចឹងកូនចៅមានបានឲ្យរៀនទេ?

សឿតៈ អត់!ដល់ក្រោយមកដុតពីនោះមកទៅនៅម្តុំយើងមុខខាងកើតអន្លង់វែងលើភ្នំនោះ អាហ្នឹងគេមានសាលាគេហើយ គេរៀនមិនបានថ្នាក់ខ្ពស់ប៉ុន្មានទេ វាចេះរបស់វាដែរ តែបានភាគតិចណាស់ ភាគច្រើនគ្នាមិនបានសិក្សាទេ ពីមុនមិញនោះគ្មានសាលាអីរៀនទេ ចុះមកក៏រៀនតាមគ្រូអីតិចតួចគ្រូខ្វះគ្នា មិនចេះអីផងឲ្យគ្នាបង្រៀនគ្នាចេះតែបង្រៀនទៅ ដូចខ្ញុំថាមិញដូចខ្ញុំនេះខ្ញុំរៀនអក្ខកម្មដែលហ្នឹង ។

វណ្ណៈ ចឹងកាលពូនៅក្នុងសម័យបីឆ្នាំនិងក្រោយ៧៩ហ្នឹងអត់មានឋានៈធំដុំទេ?

សឿតៈ ទេ ។

វណ្ណៈ ចឹងបានត្រឹមកូនចៅជាអង្គរក្សការពារ?

សឿតៈ បាទ!ត្រឹមអង្គរក្សគេដុតអង្គរក្សជាយុទ្ធជនរហូតមកដល់គេឲ្យជាប់គុកតែគេឲ្យដើរដី១០០ម៉ែត្របួនជ្រុង ។

វណ្ណៈ ចឹងកាលហ្នឹងពូបានរៀបការអីឆ្នាំណាដែរ?

សឿតៈ ខ្ញុំការឆ្នាំ៧៧ គេរៀបឲ្យដូចស្វាអង្គុយលើកៅអី ។

វណ្ណៈ ចឹង៧៧ហ្នឹងរៀបការប៉ុន្មានគូរកាលហ្នឹង?

សឿតៈ បីគូរ ។

វណ្ណៈ ចឹងតែបីគូរតិចដែរ?

សឿតៈ បាទ ។

វណ្ណៈ ពូស្រឡាញ់ទៅជ្រើសរើសឲ្យប្ដីមួយចាប់គូរឲ្យតែម្ដង?

សឿតៈ អត់មានស្គាល់គ្នាផង គេកុហកខាងនេះគេកុហកខាងនោះទៅជួបទៅអង្គុយៗម៉ែឪមកអង្គុយលើដីចេះមើលមុខកូនៗអង្គុយលើកៅអីដូចស្វាចិន ដូចខ្ញុំនិយាយចឹង ។

វណ្ណៈ ចឹងបានហៅម៉ែឪមកមើលដែរ?

សឿតៈ ហៅបើការនៅស្រុកហ្នឹង មែនទែនការនៅភូមិប្រពន្ធខ្ញុំហ្នឹង ភូមិខ្ញុំនៅឆ្ងាយដែរ គេហៅម៉ែខ្ញុំឪខ្ញុំមកដែរ ។

វណ្ណៈ ចឹងប្រពន្ធពូជាអ្នកស្រុកព្រះវិហារដែរ?

សឿតៈ បាទ ។

វណ្ណៈ ចឹងនៅស្រុកជាមួយគ្នាដែរ?

សឿតៈ ស្រុកជាមួយគ្នាតែភូមិខុសគ្នា ចម្ងាយគ្នាប្រហែលជាបួនទៅប្រាំគីឡូ ។

វណ្ណៈ ចឹងក្រោយមកពូចេញពី១០០៣ពូទៅខាងណាទៀតទៅ?

សឿតៈ ចេញពី១០០៣មកអត់មានទៅណាទេ នៅតែក្បែរហ្នឹងមុខអន្លង់វែង៨០៨ហ្នឹងទល់មុខអន្លង់វែង ។

វណ្ណៈ ចេញ១០០៣នៅ៨០៨វិញ?

សឿតៈ បាទ ។

វណ្ណៈ ៨០៨នៅម្ដុំណា?

សឿតៈ នៅលើភ្នំនៅក្បាលអូរស្វាយនៅជាំ ។

វណ្ណៈ ចឹងនៅម្ដុំហ្នឹងគេហៅ៨០៨?

សឿតៈ បាទ ។

វណ្ណៈ ចឹង៨០៨ហ្នឹងតាម៉ុក គាត់កាន់កាប់ដដែលប្ដីមួយមានពីណាកាន់នៅហ្នឹង?

សឿតៈ តាម៉ុក ។

វណ្ណៈ មានពីណាផ្សេងទៀតទេ?

សឿតៈ អត់ទេ មានតែតាម៉ុក មួយច្រកហ្នឹង ។

វណ្ណៈ ចឹងខ្ញុំចង់ដឹងបន្តទៀតថា តាម៉ុក ពេលនៅ៨០៨ហើយ ក្រោយមកទៀតគាត់ធ្វើដូវចុះពីលើភ្នំនៅឆ្នាំណាដែលបានមកនៅជាភូមិនេះ ចុះមកនៅខាងក្រោមលែងនៅលើភ្នំលែងនៅ៨០៨លែងនៅ១០០៣ ចុះមកនៅខាងក្រោមបង្កើតជាភូមិនៅឆ្នាំណា?

សឿតៈ ៨០ប៉ុន្មានទេ ខ្ញុំអត់ចំណាំដែរ ខ្ញុំមិនបានចាំដែរ ។

វណ្ណៈ: ចុះមកកាលហ្នឹងមុនអ៊ុនគាត់ចូលឬមួយក៏យ៉ាងម៉េច?

សឿតៈ ជំនាន់អ៊ុនគាត់ហ្នឹងឯង ចុះមករៀបចំខាងក្រោមហ្នឹង ។

វណ្ណៈ: តែមុនអ៊ុនគាត់មួយឆ្នាំឬពីរឆ្នាំឬសម័យអ៊ុនគាត់?

សឿតៈ មុនអ៊ុនគាត់មួយឆ្នាំតាមខ្ញុំដឹង ។

វណ្ណៈ: ចឹងប្រហែលជាឆ្នាំ១៩៩០-៩១តាម៉ុក ធ្វើផ្លូវចុះមក?

សឿតៈ បាទ!ហ្នឹងហើយ កាលតាម៉ុក ដាច់ដើងហ្នឹងដោយសារគាត់ធ្វើផ្លូវចុះហ្នឹងឯង ។

វណ្ណៈ: ចឹងកាលពូចុះមកក្រោយហ្នឹងពូមកដល់ហ្នឹងតែម្ដងឬមួយពូនៅអន្លង់វែងឬនៅអូរស្វាយឬមួយនៅណា?

សឿតៈ ខ្ញុំចុះមកនៅមុខជុបរុនយើងនេះឯង នៅជើងភ្នំនេះ គេហៅប្រកព្រះប្រឡាយជុបរុនហ្នឹងអត់មានអន្លង់វែងអត់មាននៅណាទេ ។

វណ្ណៈ: ចឹងនៅជុបរុន?

សឿតៈ បាទ!ចុះមកជុបរុនហ្នឹងឯង ប្រកព្រះប្រឡាយហ្នឹង ។

វណ្ណៈ: ជុបរុនគេហៅកងណានៅជុបរុន?

សឿតៈ ជុបរុន មុនមិញនៅ៦១៧-៦១៦នៅនោះដែរ ក្រោយមក៦១៦គេយកទៅនៅខាងលិចទៅនៅខាងផ្លូវនោះ ។

វណ្ណៈ: នៅផ្លូវខាង១០៥ហ្នឹង?

សឿតៈ បាទ ។

វណ្ណៈ: ចឹងពូនៅខាងជុបរុនអស់រយៈពេលប៉ុន្មានបានមកនៅភូមិនេះ?

សឿតៈ ខ្ញុំមែនទែនចុះពីលើនោះឆ្នាំប៉ុន្មានឆ្នាំ៨៩ហើយអ!៨៨ហ្នឹងឯងចុះពីលើភ្នំមក មកនៅជុបរុន ។

វណ្ណៈ: ចឹងឥឡូវពូចេញពីជុបរុនមក មកនៅណា?

សឿតៈ ខ្ញុំមកនៅនេះ ។

វណ្ណៈ: ឆ្នាំណាមកនៅនេះ?

សឿតៈ ខ្ញុំមកនៅនេះឆ្នាំ២០០២ ។

វណ្ណៈ: ចឹងនៅភូមិនេះរាល់ថ្ងៃគេដាក់កងពលលេខប៉ុន្មាន៦១៧ឬក៏លេខប៉ុន្មាន?

សឿតៈ ៦១៧ ។

វណ្ណៈ: ចឹងជុបរុន៦១៧ចឹងមកនៅនេះ៦១៧ដែរ?

សឿតៈ បាទ ។

វណ្ណៈ: ៦១៧ហ្នឹងកាលហ្នឹងពីណាគ្រប់គ្រង?

សឿតៈ អៀង ហឿន ។

វណ្ណៈៈ ចឹងគាត់នៅដែលទេ អៀង ហឿន ហ្នឹង?

សឿតៈ គាត់នៅតែគាត់ចូលនិវត្តន៍ហើយ ។

វណ្ណៈៈ ក្រែងតាហឿន គាត់នៅខាងមណ្ឌលគិរីឥឡូវនេះ ក្រែងគាត់ពាក់ផ្កាយហើយ?

សឿតៈ បាទ!គាត់ផ្កាយ តែគាត់អាត្រែតហើយ ។

វណ្ណៈៈ ចឹងជុបរុន៦១២មកនៅភូមិនេះ៦១២ដែរ?

សឿតៈ បាទ!៦១២ តែឥឡូវនេះគេបំបែកមកតាមឃុំតាមស្រុកក៏គាត់លែងកាន់កាប់ហើយមានគេអ្នកផ្សេងក្តាប់ហើយ ចឹងគាត់អាត្រែតអស់ហើយគាត់អត់មានអីទៀតទេ ។

វណ្ណៈៈ ចឹងយ៉ាងម៉េចបានគេដាក់៦១២កន្លែងខ្លះដាក់ភូមិ៨៩ចឹងយ៉ាងម៉េចបានជាគេដាក់ចឹង?

សឿតៈ អានោះខ្ញុំអត់យល់ដែលអាចថា តាមមើលទៅតាមខ្ញុំយល់អាចថា គេចែកចេញពីកងពលមក វរៈធំវរៈតូចអីចឹងបានគេដាក់លេខតាមមើល តាមខ្ញុំស្មានទេ ។

វណ្ណៈៈ ចឹងភូមិហ្នឹងម៉េចបានគេដាក់ឈ្មោះ ភូមិអូររំដួលនេះកើតឆ្នាំណា?

សឿតៈ ភូមិអូររំដួលនេះកើតឆ្នាំសមាហរណ៍កម្មហ្នឹងហើយ ។

វណ្ណៈៈ ចឹងភូមិថ្មីទេ មិនមែនភូមិតាំងពីដើមមកទេ?

សឿតៈ អត់ទេ!មុនមិញសុទ្ធតែជាតំបន់ព្រៃខ្លាដំរីសត្វព្រៃ ។

វណ្ណៈៈ ចឹងកាលពូចុះមកដល់ដំបូងមានសត្វព្រៃ ព្រៃឈើច្រើនទេកាលហ្នឹង?

សឿតៈ និយាយពីព្រៃឈើ និយាយពីដើមឈើនោះយើងវាស់មួយជុំមកលាតមកអាខ្លះមាន៥ម៉ែត្រ អីនោះ ឈើទាល គគីរ ផ្ចឹក...។

វណ្ណៈៈ ចឹងក្រោយមកម៉េចបានអស់ព្រៃឈើចឹងដោយសារអីទៅ?

សឿតៈ គេកាប់ចម្ការផង គេអារធ្វើផ្ទះផង ។

វណ្ណៈៈ អារលក់ផង?

សឿតៈ បាទ ។

វណ្ណៈៈ ចុះគេនិយាយថា ពេលផ្តាច់ជំនួយតាម៉ុក គាត់ធ្វើផ្លូវអីហ្នឹង ដើម្បីកាប់ឈើលក់ឲ្យថៃជាការពិតមែនឬមួយយ៉ាងម៉េច?

សឿតៈ ពិត តាម៉ុក ធ្វើបានមួយឆ្នាំកាប់ឈើលក់ ។

វណ្ណៈៈ ចឹងកាប់កាលហ្នឹងអាចថារាប់សែនម៉ែត្រគីបឬមួយយ៉ាងម៉េច មានដឹករាល់ថ្ងៃឬយ៉ាងម៉េច?

សឿតៈ	ដីករាល់ថ្ងៃ មិនដឹងជាប៉ុន្មានគីបខ្ញុំមិនយល់ដែរ និយាយពីដីកគរពេញជើងភ្នំនៅមុខជុបរុនហ្នឹង តែធ្វើមិនបានយូរទេ កុងត្រាតាម៉ុក ៥ឆ្នាំ តែខាងរដ្ឋាភិបាលមានសកម្មភាពខ្លាំងទៅធ្វើបាន តែមួយឆ្នាំ ឈើខ្លះនៅសល់ពុកផុយចោល ភ្លើងឆេះចោល ។

វណ្ណៈ	ចឹងពួខ្លះថាដុតចោលទៀត?

សឿតៈ	បាទ ។

វណ្ណៈ	ចឹងកាលហ្នឹងយ៉ាងម៉េចបានដុតចោលយើងមិនទុកចោលសិនទៅ?

សឿតៈ	ទុកចោលអីមិនមែនដុតទេ ភ្លើងព្រៃឆេះតែម្ដង មានពីណាការពារវាបើស្មៅវាដុះមកពេញ ហើយ ចុះពេលងាប់ទៅភ្លើងស្មៅឆេះមករាល ។

វណ្ណៈ	តាមពិតនៅនេះសម្បូរប្រភេទឈើអីល្អច្រើនទេ?

សឿតៈ	ឈើគគីរ ផ្ចឹក ឈើទាល មានតែបីប្រភេទទេ ។

វណ្ណៈ	ចឹងបេងក្រញូងអី?

សឿតៈ	អើ!និយាយពីបេងក្រញូង បើនិយាយពីក្រញូងមហា កាលនោះពួកខ្ញុំអីកាប់ចម្ការរំលំចោល ដើមប៉ុនៗនេះរំលំចោលកុំឲ្យស្រោងខូចស្រូវខូចអី ។

វណ្ណៈ	កាលហ្នឹងយើងមិនស្គាល់ក្រញូងដែលទេ?

សឿតៈ	ស្គាល់តែមិនបានដឹងថា ឈើក្រញូងមានតម្លៃអីយើងមិនបានដឹង ។

វណ្ណៈ	ចឹងដុតចោលអស់?

សឿតៈ	ដុតចោល ។

វណ្ណៈ	ស្ដាយឥឡូវរាប់ម៉ឺនរាប់សែន?

សឿតៈ	បាទ!ក្នុងមួយដើមពីរម៉ែត្រក្នុងមួយស្មើនិងបួនកំណាត់ហើយយប់ឡើងដេកភ្ញាក់ឡើងងើបឡើង យកឈើទៅគាស់ប្រមៀលឲ្យវាឆេះអស់ទុកដាំស្រូវឲ្យល្អ ក្រោយមកឈើក្រញូងមានតម្លៃ បានស្ដាយ កុំអីខ្ញុំដល់ហើយក្រញូង ក្រោយមកដឹងថាឈើមានតម្លៃមានគេអ្នកមករកថា បង ឈើក្រញូងនេះខ្ញុំ ខ្ញុំអារឲ្យបងឯងគ្រែមួយគ្រឿង ខ្ញុំថាយកទៅ៤-៥ទៅ៦ដើមឲ្យគ្រឿង គ្រែមួយគ្រឿងមិនបានផង អាក្បាំងនេះក៏អត់បាន បានតែអាមេនេះហើយនិងជើងវានេះ យកធ្នងអីណាមកដាក់ ចាញ់បោកគេ គេយកលុយទៅចាយគេយកឈើ៥-៦ដើមឲ្យឯងគ្រែ មិនបានមួយគ្រឿងគ្រែផង ។

វណ្ណៈ	ចឹងកាលហ្នឹងគេធ្វើចឹង បើគេទិញទៅដឹងថ្លៃផ្អើល?

សឿតៈ	បាទ ។

វណ្ណៈ	ចឹងទុកជាការដោះដូរវិញ?

សឿតៈ ហ្នឹងហើយ សុខចិត្តគេសួរយើងថាមានឈើចេះឲ្យគេទៅគេអារឲ្យឈើមួយគ្រឿងគ្រែ ឈើហ្នឹងគេយកតែតម្លៃប៉ុន្មានយើងមិនដឹងទេ បើបានប៉ុណ្ណោះអរ កំពុងតែចង់បានគ្រែដែរ តាមពិតគេឲ្យមិនបានគ្រប់មួយគ្រែផង រកពីណាមកប៉ះប៉ូវទៀត ។

វណ្ណៈ ចឹងគេកាប់ឈើដាក់ឡានទៅអស់?

សឿតៈ បាទ! គេយកទៅអស់ ។

វណ្ណៈ ចឹងខ្ញុំចង់សួរពេលជិតសមាហរណ៍កម្មមែនទែនហ្នឹង ឃើញខាងត្រពាំងប្រាសាទអន្លង់វែងមានការរគ្រោះរង្គើលច្រើនរហូតខាងខ្មែរក្រហមដូចគ្នាមិនទុកចិត្តគ្នា ឈានដល់សម្លាប់តាសុន សេន ក្រោយមកចាប់តាប៉ុល ពត កាត់ទោសអីហ្នឹង តើជាបញ្ហាអីបានឈានដល់ថ្នាក់សម្លាប់គ្នាឯង?

សឿតៈ ខ្ញុំអត់យល់ដែលរឿងហ្នឹង រឿងផ្ទៃក្នុងរបស់មេៗខាងលើ ខ្ញុំមិនយល់ កំពង់ធ្វើជាមួយស្រាប់តែថា អានេះចេះអានោះចុះ មិនដឹងជាបែងចែកគ្នាគាត់យ៉ាងម៉េច ។

វណ្ណៈ ចឹងកាលសុន សេន ស្លាប់ពូមានបានទៅមើលទេ?

សឿតៈ ខ្ញុំអត់ទេ ខ្ញុំមិនដែលបានស្គាល់មុខផងខ្ញុំ មិនដឹងជាមុខយ៉ាងម៉េច ខ្ញុំស្គាល់មុខច្បាស់មានតែតាម៉ុក មួយទេ ខុសពីហ្នឹងមិនដែលស្គាល់ទេ ។

វណ្ណៈ ចឹងពូអត់មានដឹងថា តានួន ជា តាខៀវ សំផន តាសុន សេន តាប៉ុល ពត មកនៅលើភ្នំខាងក្បាលទន្សោងហ្នឹង ពូមានបានដឹងទេ មានដឹងថាគាត់មកឆ្នាំណាដែរ?

សឿតៈ ខ្ញុំមិនបានចាំទេ ។

វណ្ណៈ ចឹងកាលតាម៉ុក កាត់ទោសលោកប៉ុល ពត អីពូមានបានទៅចូលរួមទេ?

សឿតៈ ខ្ញុំទៅចូលរួមមតិនៅសាលាខេត្តឧត្តរមានជ័យយើងនេះ ។

វណ្ណៈ ខ្ញុំចង់និយាយគេធ្វើកន្លែងកាត់ទោស ប៉ុល ពត នៅលើភ្នំពូមានបានទៅទេ?

សឿតៈ អត់ទេ ។

វណ្ណៈ ចឹងអត់បានទេ?

សឿតៈ អត់ទេ ខ្ញុំអត់បានដឹងផង ខ្ញុំប្រជាពលរដ្ឋគេអត់មានហៅទៅទេ ។

វណ្ណៈ ចឹងក្រោយមកទៀតក្រោយពីសម្លាប់តាសុន សេន ទៅគេមានចាប់តាសារឿន០៥តា០៦អីនិងមានមនុស្សមួយចំនួនទៀតយកទៅដាក់ទ្រុងហើយយកទៅសម្លាប់ចោលហ្នឹងពូមានដឹងទេ?

សឿតៈ ដឹង តែខ្ញុំមិនបានដឹងថាគេយកទៅសម្លាប់ត្រង់ណាខ្ញុំមិនបានដឹង តែគ្រាន់ដឹងថាតាម៉ុក គាត់ជាអ្នកឲ្យយកទៅសម្លាប់ តែស្លាប់ត្រង់ណាមិនបានដឹង ។

វណ្ណៈ ចឹងសភាពការណ៍ពេលហ្នឹងមានរឿងអីកើតឡើងខ្លះ តើមានការព្រួយបារម្ភអីដែរ?

សឿត៖ កាលនោះបើនិយាយពីការព្រួយបារម្ភណ៍របស់ប្រជាពលរដ្ឋ ស្ទើនិងសម័យប៉ុល ពត រយៈពេលបីឆ្នាំ ខ្ញុំនិយាយត្រង់ខ្ញុំព្រួសូរឡានតូចដើរយប់ពុងឺៗ ខ្ញុំធើបអត្តុយបារម្ភណ៍ណាស់ មិនជាចាប់នរណាទៀតទេ កាលហ្នឹងផ្ទៃក្នុងដូចជាយ៉ាងម៉េចទេ ដូចថាមិនទុកចិត្តគ្នាឯង យើងមិនដឹងដែរ យើងមិនបានដឹងនយោបាយខាងលើ បងប្អូនប្រជាពលរដ្ឋបារម្ភណ៍ណាស់ពេលហ្នឹង។

វណ្ណៈ៖ ចឹងកាលហ្នឹងមានការចាប់ចុះឡើងចឹងមានការបារម្ភណ៍ដែរ?

សឿត៖ បាទ។

វណ្ណៈ៖ ហើយដូចជាក្រោយមកទៀតមានសមាហរណ៍កម្មចូលជាមួយរដ្ឋាភិបាលអីហ្នឹង កាលហ្នឹងពីណាជាអ្នកដឹកនាំចូល ដូចថាដឹកនាំចូលទៅខាងរដ្ឋាភិបាលផ្ដាច់ខ្លួនពីតាម៉ុកអីចឹង មានពីណាគេខ្លះដែរ?

សឿត៖ ជំនាន់នោះមានមេច្រើនខ្ញុំមិនបានដឹងថាពីណាដែរ កាលនោះក្រោមបទបញ្ជាមានតែ អៀង ហឿន ហ្នឹងឯង សៅ ថាន វ៉ាន់កុសល្យ។

វណ្ណៈ៖ មាន ជុំ ជាតិ ដែរ?

សឿត៖ បាទ!ជុំ ជាតិ ដឹងថាគាត់ហើយមេនាំទៅដែលគេថ្កោលទោសគាត់ គាត់ទៅបានប៉ុន្មានខែគេជេរនេះ ពួកខ្ញុំប្រជាពលរដ្ឋគេហៅមកប្រជុំ គេជេរគេថា កុំឆ្កួតតាមអាជុំ អាកែវ ចឹងណាស់ គេអប់រំពួកខ្ញុំបន្ទាប់ពីហ្នឹងគេឲ្យខ្ញុំទៅដឹកជញ្ជូននៅដូវអានសេះនេះ ស្រាប់ឃើញបងជុំ ដែលដឹង ឃើញគេអ្នកផ្សេងបើកយន្តហោះបាចត្រាក់នៅខាងលិចអានសេះនេះ ឃើញឈ្មោះបង ជុំ ជាតិ ហើយតាកែវអី គាត់អំពាវនាវនាយទាហានពលទាហានទាំងអស់ សូមឲ្យចុះចូលជាមួយរដ្ឋាភិបាល គាត់បានទៅបំប៉នសុខភាពនៅភ្នំពេញប៉ុន្មានថ្ងៃប៉ុន្មានខែ ឯងទៅមើលគេមើល ឯងមកជាមួយអញមក គាត់អំពាវនាវខ្ញុំមើលដឹងថា បងជុំ ជាតិ ទៅដល់នោះតើ។

វណ្ណៈ៖ ចឹងប្រជាជនពេលបានមើលត្រាក់ហើយមានការពិចារណាប្រជុំគ្នាទេ?

សឿត៖ មានការពិចារណា តែមិនហ៊ាននិយាយចំហទេ មានគេខ្លះគេនៅវីងវ៉ឹង គ្រាន់តែមាននិយាយខ្សិបខ្សៀវគ្នា កាលហ្នឹងមានបង ជុំ បងកែវ គេទៅអស់ហើយចឹងយើងទៅណា មិនដឹងជាទៅបើគាត់ទៅចោលយើងបាត់ហើយ យើងទៅតាមណាបាន ក្រោយមកបានផ្ដាច់ខ្លួនទ្រង់ទ្រាយបញ្ចប់ ខ្ញុំឃើញលោក សៅ ថាន ទល់មុខផ្ទះខ្ញុំនេះគាត់ដឹកនាំកម្លាំងរដ្ឋាភិបាលឡើងមកមួយរម៉ក់អាត្រាក់ចូលទៅក្នុងភូមិប្រោកបណ្ដោយ ទៅដល់ផ្ទះដៃហោត្រាវ ខ្ញុំស្មានតែមកបាញ់គ្នា គាត់ថានរណាទៅបាញ់ស្អី។

វណ្ណៈ៖ ចឹងកាលហ្នឹងឲ្យប្រជាជនចាកចេញទៅក្នុងវិញ?

សឿតៈ បាទ!ដល់គេចូលមកពេញធ្វើការអីជាមួយគ្នា គេថាបង១ នាំខ្ញុំមកលោមានគេលបស្មាក់ចាំបាញ់ អើរ!មានពីណាបាញ់ពីណា ពួកខ្ញុំចូលភ័យខ្លាចដែរ មានអីខ្លាចមានអីភ័យពួកខ្ញុំប្រជាជនហ្នឹង ។

វណ្ណៈ ចឹងពេលហ្នឹងតាម៉ុក គាត់យ៉ាងម៉េចដែលពេលមានប្រជាជនព្រុះព្រះចូលទៅខាងនោះ គាត់មានវិធានការទប់ស្កាត់យ៉ាងម៉េចដែរ?

សឿតៈ ទេ មិនដឹងថាទប់យ៉ាងម៉េចទេ តែប្រហែលជាគាត់គេចខ្លួនដែលតាមមើលស្រុកថៃតាមមើល ។

វណ្ណៈ ចឹងគាត់គេចខ្លួនដែរ?

សឿតៈ បាទ!គាត់គេចខ្លួនដែរ ។

វណ្ណៈ គាត់ដឹងថាកម្លាំងចូលទៅហើយ?

សឿតៈ បាទ!កម្លាំងចូលទៅហើយ ។

វណ្ណៈ ចឹងកាលហ្នឹងមេកងពលចូលទៅអស់ហើយ?

សឿតៈ ចូលទៅអស់ហើយ គាត់មានកម្លាំងអីទៀតមិនគេចខ្លួន ។

វណ្ណៈ ចឹងកម្លាំងខាងហ្នឹងចូលខាងអន្លង់វែងឬខាងអន្លង់វែងគេចូលទៅមុន?

សឿតៈ ព្រមគ្នាតែមានមុនមានក្រោយខាងអន្លង់វែងក៏មានមុនក្រោយខាងត្រពាំងប្រាសាទក៏មានមុនក្រោយដែរ ដល់ពេលគេមើលទៅវាយូរពេកគេលែងទុកចិត្តតាម៉ុក ហើយគេមកអស់ហើយ ៩០ភាគរយគេមកនៅសល់១០ភាគរយទៅធ្វើអីចេញ ហើយគេមកតាមក្រោយមកអស់យើងមកជួបជុំគ្នាយើងនៅធ្វើអីទៀត តស៊ូអីទៀត ។

វណ្ណៈ ចឹងទ្រុងរាល់ថ្ងៃនៅផ្ទះតាម៉ុកហ្នឹងជាទ្រុងដាក់មនុស្សឬមួយជាទ្រុងដាក់ស្ដីដែរ?

សឿតៈ ខ្ញុំមិនបានដឹងដែរ ។

វណ្ណៈ ចឹងពូមិនដែលទៅមើលទេ ទ្រុងនៅផ្ទះតាម៉ុក?

សឿតៈ ខ្ញុំមិនដែលបានទៅមើលទេ មុនមិញនោះមិនងាយចូលមើលបានផ្ដេះផ្ដាស់ទេ ។

វណ្ណៈ តែឥឡូវយើងអាចទៅមើលបាន?

សឿតៈ បាទ!តែឥឡូវមិនបានទៅមើល មុនបើគ្មានការចាត់តាំងទេ អត់មានដើរឆ្វេកឆ្វាបបានទេ ។

វណ្ណៈ ចឹងតាម៉ុក តាំងពីក្រោយ៧៩រហូតដល់មានខាងរដ្ឋាភិបាលចាប់ខ្លួនហ្នឹង គាត់បានកសាងអីច្រើនដែលឬក៏មិនសូវបានទេ?

សឿតៈ កាលនោះគាត់នៅច្បាំងគ្នា មិនថាគាត់កសាងអី គាត់ធ្វើតែផ្លូវហើយធ្វើផ្ទះគាត់នៅកន្លែងសព្វថ្ងៃនេះនិងស្ពានអន្លង់វែង ។

វណ្ណៈ	ចឹងគេថាមានសាលារៀនមន្ទីរពេទ្យអីទៀតនោះ?

សឿតៈ	សាលារៀនមានមន្ទីរពេទ្យមានប្រើសព្វថ្ងៃមន្ទីរពេទ្យនៅប្រើសព្វថ្ងៃដែរ គាត់ធ្វើដូចថាគាត់កសាងរបស់គាត់ដែរ តែស្ថិតនៅក្នុងសម័យដែលច្បាំងគ្នា គាត់អាចឆ្លៀតឱកាសធ្វើបានរបស់គាត់ដែរ សាលារៀននៅសព្វថ្ងៃតើ ។

វណ្ណៈ	ចឹងកាលហ្នឹងខាងពួជ្ដាច់ខ្លួនមិនបានបោះឆ្នោតនៅឆ្នាំ១៩៩៣ទេ?

សឿតៈ	បោះតើ ។

វណ្ណៈ	បានបោះដែរ?

សឿតៈ	បោះកាលនោះ តាម៉ុក អត់ទាន់ចូលទេ ខ្ញុំពួកខ្ញុំបោះឲ្យមានកាលនោះពួកមិនផ្ដាច់ខ្លួនទៅបំផ្លាញសន្លឹកឆ្នោតម្ដុំផ្លូវ ដឹងដែលកាលនោះ ។

វណ្ណៈ	ខ្ញុំឮគេនិយាយដែរ ។

សឿតៈ	ហ្នឹងហើយពួកខ្ញុំបោះឲ្យហ្នឹង ។

វណ្ណៈ	ចឹងបោះឲ្យខាងណាកាលហ្នឹង?

សឿតៈ	បោះឲ្យខាងរដ្ឋាភិបាលកាលនោះ ។

វណ្ណៈ	ចឹងបោះក្រោយទៀតទេ បោះអាណត្តិក្រោយទៀតទេ បោះ៩៣ ខាងខ្មែរក្រហមតាមខ្ញុំដឹងមិនទាន់ត្រូវជាមួយរដ្ឋាភិបាលទេ ខ្មែរក្រហមកាលឆ្នាំ៩៣បោះជួយខាងហ៊ុនស៊ិនប៉ិច ក្រោយមកខាងហ៊ុនស៊ិនប៉ិចឈ្នះឆ្នោតបាននាំកម្លាំងរដ្ឋាភិបាលវាយខាងតាម៉ុកវិញ ដឹកនាំដោយ ញឹកប៊ុនឆៃ?

សឿតៈ	អើ ។

វណ្ណៈ	ក្រោយមកមានសមាហរណ៍កម្ម៩៨ហើយបានជួយបោះឲ្យខាងរដ្ឋាភិបាល?

សឿតៈ	បាទ ។

វណ្ណៈ	ចឹង?

សឿតៈ	បាទ ។

វណ្ណៈ	កាលនោះខាងខ្មែរក្រហមមិនមានឈរឈ្មោះបោះឆ្នោតបានទេ?

សឿតៈ	អត់មានទេ ។

វណ្ណៈ	ចឹងពូអាចមួយវគ្គហ្នឹង?

សឿតៈ	ហ្នឹងហើយ ។

វណ្ណៈ	ចឹងអាចបោះវគ្គទី២ទេ?

សឿតៈ	បាទ ។

វណ្ណៈ ព្រោះយើងមានអាណត្តិ៥ឆ្នាំម្តង?

សឿតៈ ហ្នឹងហើយ ។

វណ្ណៈ ចឹងពូមានចាំសមាហរណ៍កម្មទេ សមាហរណ៍កម្មឆ្នាំណា?

សឿតៈ សរសេរទុកដែលតែមិនបានចាំ ។

វណ្ណៈ តាមខ្ញុំដឹងឆ្នាំ៩៨អីហ្នឹង?

សឿតៈ បាទ!៩៨ថ្ងៃទីប៉ុន្មានទេ ខ្ញុំសរសេរទុកដែលតែមិនបានចាំ ។

វណ្ណៈ ចឹងដោយសារពូធ្លាប់ឆ្លងកាត់សម័យកាលច្រើនដែរ ខ្ញុំចង់សួរថា កាលសម័យសង្គ្រាមហ្នឹង បច្ចុប្បន្នតើវាមានភាពខុសគ្នាយ៉ាងម៉េចដែរ មកដល់ឥឡូវសម័យណាមួយដែលរស់នៅស្រួលជាង?

សឿតៈ សម័យសង្គ្រាមយើងមានទៅស្រួលស្អី សម័យយើងបន្ទួរឈាមថ្ងៃណាក៏ថ្ងៃព្រាត់ប្រាស់ពីប្រពន្ធកូន គេប្រើទាំងយប់ទាំងថ្ងៃសម័យនេះ សម័យយើងនៅសុខសាន្តជាមួយប្រពន្ធកូនយើងបានស្រួលមែនទេ ចង់ទៅណាក៏បាន ចង់ដេកៗចង់ដើរៗ សម័យនោះសម័យច្បាំងគ្នានេះមកពីសមរភូមិបានតែមួយយប់ចេះ ព្រឹកឡើងគេហៅទៅផ្ទុះបាត់នោះ សម័យនេះវាមហាអស្ចារ្យហើយ ។

វណ្ណៈ ចឹងមកដល់ឥឡូវពូខស្សាហ៍ទៅលេងស្រុកកំណើតផ្ទាល់ហើយតើ?

សឿតៈ ខ្ញុំទៅរាល់ឆ្នាំ ។

វណ្ណៈ ចឹង?

សឿតៈ បាទ!មួយឆ្នាំជួនណាទៅម្តងឬពីរដងទៅសួរសុខទុក្ខបងប្អូន ។

វណ្ណៈ ចឹងរឿងរ៉ាវដែលពូធ្លាប់ឆ្លងកាត់កន្លងមកពូមានដែលនិយាយរឿងរ៉ាវប្រាប់ក្មេងៗជំនាន់ក្រោយឲ្យបានដឹងទេ មានដែលនិយាយប្រាប់សម័យកាលតស៊ូនិងដែលពូ?

សឿតៈ និយាយតើ ខ្ញុំច្រើនតែប្រៀបធៀប កូនចៅខ្លះវាអស់សំណើចថា កូនអើយជំនាន់អញ ឯងមើលមើមដំឡូងនេះ ស្លឹកដំឡូងនេះ ម្ហូបឆ្ងាញ់គួរសម បើនិយាយពីបាយវិញប្រហែលជ្រូកដែរ ខ្ញុំធ្លាប់និយាយប្រាប់វាចឹង ឪពុកគេហូបយ៉ាងម៉េច មានហូបយ៉ាងម៉េចយើងកើតៗយើងហូបមិនកើតអត់ទៅ ចុះទៅរកអីហូបទៀតក្រៅពីហ្នឹង ស្វាទោសសត្វស្វាគេបាញ់បានមកទាំងអំរែកគេឡោតបកស្បែកបានដាក់ស្ងោខ្លះប៉ុននេះឲ្យផុយរលួយអស់ចេះ ដាក់ទាំងក្បាលទាំងជើងទាំងដៃទាំងអស់ គេស្រងតែឆ្អឹងកាលនោះគេទិញឆ្អឹង មួយគីឡូស្មើ៥០០ កាលនោះនៅប្រើលុយជំនាន់សម្តេចតាយើងនោះឆ្នាំ៧០-៧១-៧២នោះ ខ្ញុំលក់មកដល់ស្មោងមកដល់កំពង់ក្តីនេះ ។

វណ្ណៈ៖ ចឹងសម័យនោះយើងកុំនិយាយ យើងចង់និយាយសម័យបីឆ្នាំវិញ ការហូបចុកយ៉ាងម៉េចដែរ កាលហ្នឹង មានដែលនិយាយប្រាប់ក្មេងទេកាលសម័យបីឆ្នាំ?

សឿតៈ នោះដែលខ្ញុំនិយាយប្រាប់មិញដែលថា ដាក់បបរដំឡូងអីហ្នឹងដែលខ្ញុំនិយាយមិញហ្នឹង ។

វណ្ណៈ៖ ចឹងសម័យឥឡូវយើងបានហូបគ្រប់គ្រាន់?

សឿតៈ សម័យឥឡូវខ្ញុំប្រៀបធៀបទៀតខ្ញុំថា សម័យមុនអ្នកធ្វើការអត់មានពីណាទំនេរម្នាក់មិនថា អ្នកតូចអ្នកធំមិនថាអ្នកមានអ្នកក្រ ដេញឲ្យធ្វើការទាំងអស់តែហូបបបរ សម័យនេះគេដេកស៊ី គេអ្នកមានគេមិនធ្វើការផង គេស៊ីចាក់ប្រាស ហើយយើងអ្នកធ្វើក៏យើងស៊ីចាក់ប្រាសដូចគ្នា យើងធ្វើបានតិចយើងស៊ីតិចយើងធ្វើបានច្រើនយើងស៊ីច្រើន យើងធ្វើដោយខ្លួនយើង ។

វណ្ណៈ៖ ចុះកាលសម័យសម្ដេចសីហនុយើងនៅជាមួយឪពុកម្ដាយ កាលហ្នឹងជីវភាពបានគួរសមដែរ ឬជួបកាលលំបាកខ្លះដែរ?

សឿតៈ កាលនោះគេមិនថាមិញទេ បើយើងប្រៀបធៀបទៅមិនខុសយើងសព្វថ្ងៃប៉ុន្មានទេ អាហ្នឹង តាមធុនធានគ្រួសារមួយៗនោះណាស់ អត់មានពីណាគេយករបស់យើងទេ យើងធ្វើបាន ប៉ុន្មានយើងហូបប៉ុណ្ណោះ យើងធ្វើមិនបានក៏យើងអត់ យើងខ្ចីរបុលគេដែរ វាអត់មានខុសគ្នា ទេ តាមខ្ញុំពិនិត្យពិចារណាមើល តែសម័យនោះមិនដឹងថាវាម៉េចទេ មិនទាន់ជឿនលឿនដល់ សម័យនេះប៉ុន្មានទេ នៅស្រុកខ្ញុំនេះខ្ញុំនិយាយត្រង់អត់ដែលឃើញម៉ូតូទេ អត់មានទេ ឃើញ អាត្រាក់ទ័រគេមួយអូសរឺម៉ក់ទៅដឹកស្រូវ ថៅកែគេតាមមើលដួកទឹកដួកដី សព្វថ្ងៃមើលទៅ ឡានក្រុងឡានអីមានព្រោងព្រាត ។

វណ្ណៈ៖ ចឹងបើយើងយកសៀវភៅចងក្រងពីរបបកម្ពុជាប្រជាធិបតេយ្យនេះដាក់បញ្ចូលទៅក្នុងសាលា ក្មេងរៀនពូគិតថាជាការទប់ស្កាត់មួយឬមួយមានសារៈសំខាន់អីដែលសម្រាប់ក្មេងៗបានរៀន សូត្រពូ?

សឿតៈ បើតាមខ្ញុំយល់ខ្ញុំថា មួយជំនាន់ៗគួរតែចងក្រងជាប្រវត្តិសាស្ត្រចារទុកដែរ សម្រាប់ក្មេងជំនាន់ ក្រោយៗគួរមែន ។

វណ្ណៈ៖ ចឹងការរៀនសូត្រឲ្យចេះដឹងពីប្រវត្តិសាស្ត្រឲ្យមានចំណេះដឹងខ្ពង់ខ្ពស់ តើពូគិតថាមានសារៈ សំខាន់ទេ បើយើងបានរៀនសូត្រចេះដឹង?

សឿតៈ ហ្នឹងវាមានសារៈសំខាន់ហើយអ្វីដែលយើងរៀនចេះដឹង ពីប្រវត្តិសាស្ត្រពីជំនាន់នេះទៅជំនាន់ នោះវាម៉េចពីជំនាន់នេះទៅជំនាន់នោះវាម៉េចហ្នឹង ឲ្យក្មេងវាដឹងឲ្យវាស្គាល់ ដូចជំនាន់ពួកខ្ញុំនេះ អត់បានដឹងពីប្រវត្តិសាស្ត្រមុនៗមិញ ដូចថាក្មេងស្រករក្រោយគេឆ្លងកាត់ធ្លាប់រៀនសូត្រ គេណែនាំគេពន្យល់យើង យើងស្ដាប់គេទៅអូ!មែន ថាប្រវត្តិសាស្ត្រវាចេះ មុនមិញវាគ្មាន

សាលាគ្មានស្អី គ្មានពីណា មិនថាមិនមានគេបង្រៀនទេ នៅជនបទពេលយើងធំពេញដឹងក្តី គេកើតរដ្ឋប្រហារទៅ ក៏យើងលែងមានសាលារៀន រត់ចូលព្រៃរៀនអក្ខរកម្មវិញ និយាយឲ្យអស់រៀនឲ្យបានចេះមើលសំបុត្របាន មិនធ្វើអីទេ ។

វណ្ណៈ: ចឹងកូនចៅពូរាល់ថ្ងៃហ្នឹងបានរៀនសូត្រគ្រាន់បើដែលឬមួយយ៉ាងម៉េចពូ?

សឿតៈ កូនខ្ញុំរៀនអត់នេះទេ កូនខ្ញុំអាពីរនាក់នោះរៀនបានត្រឹមថ្នាក់ទី៧ មីមួយនោះបានត្រឹមឌីប្លូម អាមួយនេះកំពង់តែសិក្សាថ្នាក់ទី១០ហ្នឹង អាពៅគេហ្នឹង ។

វណ្ណៈ: ចឹងពូបណ្តុះអាពៅមួយឲ្យបានដល់បរិញ្ញាទៅ?

សឿតៈ បាទ!ហ្នឹងហើយ ចង់បណ្តុះអាពៅមួយហ្នឹង ។

វណ្ណៈ: ឥឡូវយើងមានសាលារៀនគ្រប់គ្រាន់ដែលហើយពីមុនវាឆ្ងាយអីចឹង?

សឿតៈ បាទ ។

វណ្ណៈ: ចឹងបញ្ហាគ្រួសារពូទាំងកូនទាំងចៅហ្នឹងរស់នៅជាមួយគ្នាមិនមានបញ្ហាអីកើតឡើងទេ?

សឿតៈ មានបញ្ហាអីទេ មានបញ្ហាដែលខ្វះដែលធ្វើមិនបានហូបគ្រប់គ្រាន់ចេះតែជជែកទាស់គ្នាតិចតួចអីហ្នឹង រឿងស្រែចម្ការអី ។

វណ្ណៈ: ចឹងរឿងស្រែចម្ការយើងគ្រោងដាំមួយឆ្នាំទៅមួយឆ្នាំហ្នឹង យើងមានគំរោងពិភាក្សាជាមួយគ្រួសារកូនចៅថា កូនប្តុក៏ប្រពន្ធហ្នឹងថា ឆ្នាំនេះយើងត្រូវដាំអី ឆ្នាំក្រោយយើងត្រូវដាំអីបែបហ្នឹងពូមានដែលពិភាក្សាដែលទេ?

សឿតៈ ចេះតែពិភាក្សាហើយប្តីប្រពន្ធ ដូចជាឆ្នាំនេះខ្ញុំពិភាក្សាមើលយាយគួរលែងដាំដំឡូងម្តងយើងគួរដាំសណ្តែកសៀងម្តង ដំឡូងបីឆ្នាំឆ្អតទាំងអស់ ខ្ញុំថាម៉ែដូរម្តងមើលដាំសណ្តែកសៀងម្តងមើល ហើយដំឡូងនេះធ្វើនឿយជាងសណ្តែកសៀងទៀត ។

វណ្ណៈ: ចឹង?

សឿតៈ បាទ!ដំឡូងទាំងដាំមានមើមហើយគាស់ គាស់ហើយកាប់ កាប់ហើយយកមកហាល ឯសណ្តែកសៀងគេទុំហើយគេប្រូតប្រមូលបានវាយក្តួងចូលបាវអស់ចិនគេយកទៅអស់ យើងដេកម៉ាស្រួល ។

វណ្ណៈ: តែឥឡូវផលដំណាំដែលយើងលក់បានហ្នឹងងាយស្រួលក្នុងការលក់ដូរដែរ?

សឿតៈ ស្រួលណាស់រាល់ តែថោកថ្លៃអាហ្នឹងជារឿងមួយដែរ បើនិយាយរួមលក់ស្រួលឲ្យតែមានមានគេមកយកដល់ផ្ទះ ។

វណ្ណៈ: បាទ ។

សឿតៈ ឲ្យតែយើងធ្វើបាន ។

វណ្ណៈ: ចឹងបញ្ហាដីធ្លីនៅក្នុងភូមិរបស់ពូហ្នឹង មានដែលជួបបញ្ហាជាមួយក្រុមហ៊ុនឬជាមួយក្រុមណាមួយដែលឬយ៉ាងម៉េច?

សឿត: ពួកខ្ញុំដូចជាអត់មានអីទេ ខាងក្រុមហ៊ុន នាយកបានឲ្យនិសិត្សមកវាស់វែងអីអស់ហើយម្តុំនេះមួយជំនាវនេះ ចឹងគេបានយល់ព្រមអស់ហើយ មានប្លង់មានអីរបស់គាត់អស់ហើយ អត់មានអីទៀតទេ ។

វណ្ណៈ: ចឹងពូរាល់ថ្ងៃហ្នឹងមានដីប៉ុន្មានហិចតាដែរ?

សឿត: ខ្ញុំនៅនេះចង់ថាមួយជីវិតខ្ញុំមិនមានដីណាច្រើនទេ សរុបយ៉ាងច្រើនខ្ញុំមានដីត្រឹម៥ហាត់ទាំងចម្ការទាំងស្រែ ។

វណ្ណៈ: ទាំងកូនចៅ?

សឿត: បាទ!ខ្ញុំកាលនោះអត់មានចង់បានស្អីផងកាលនោះ ខ្ញុំថាដីធ្វើមិនបានផង យើងហួងហែងអីបើយើងធ្វើមិនបានផង ចឹងខ្ញុំគិតថាធ្វើបានប៉ុន្មានយកប៉ុណ្ណឹង ។

វណ្ណៈ: ចឹងបញ្ហាសាសនានៅក្នុងភូមិហ្នឹងមានដែលឬក៏យ៉ាងម៉េចដែរ មានវត្តមានអីទេ?

សឿត: មានតើ ។

វណ្ណៈ: ចឹងពូកាន់សាសនាអីដែលរាល់ថ្ងៃហ្នឹង?

សឿត: ខ្ញុំសាសនាព្រះពុទ្ធហ្នឹង ។

វណ្ណៈ: ចឹងពូយល់ឃើញយ៉ាងម៉េចដែលសាសនាព្រះពុទ្ធអាចអប់រំឲ្យយើងធ្វើអំពើល្អឬមួយអាក្រក់យ៉ាងម៉េចដែរ?

សឿត: បាទ!សាសនាព្រះពុទ្ធអប់រំចិត្តមនុស្សឲ្យស្គាល់បាបស្គាល់បុណ្យ កុំបំពារបំពានរំលោភឬក៏លួចឆក់ប្លន់គេ ព្រះពុទ្ធអប់រំល្អណាស់ ខុសពីច្បាប់រដ្ឋដែរ ប៉ុន្តែព្រះពុទ្ធអប់រំអ្វីដែលទប់ស្កាត់លឿនដូចជាច្បាប់របស់រដ្ឋទេ រដ្ឋឯងធ្វើខុសចាប់ដាក់ទោសៗ បើច្បាប់ព្រះពុទ្ធនិយាយរឿងបាបកម្មអី យើងគួរតែសិក្សា ហៅថាអប់រំមនុស្សឲ្យមានចិត្តទន់ឲ្យចិត្តស្គាល់ខុសស្គាល់ត្រូវកុំរំលោភបំពាន កុំលួចឆក់ប្លន់គេ ។

វណ្ណៈ: ចឹងពូដូចជាសម័យខ្មែរក្រហមមានវត្តអារាមអីទេ?

សឿត: សម័យខ្មែរក្រហមបំផ្លាញតាំងពីបដិមាករចោល ។

វណ្ណៈ: ចឹងសម័យពីដើមសម័យសង្គមរាស្ត្រនិយមអី យើងមានដែលឬយ៉ាងម៉េច?

សឿត: មាន សម័យសង្គមរាស្ត្រនិយមមានដូចសម័យយើងរាល់ថ្ងៃចឹង គេគោរពណាស់ព្រះពុទ្ធសាសនា បុណ្យទាន ចូលឆ្នាំ ភ្ជុំបិណ្ឌ មាឃបូជា និយាយថាដូចសព្វថ្ងៃនេះ បុណ្យផ្កាបុណ្យអីធ្វើគ្រប់សព្វ មានតែជំនាន់ខ្មែរក្រហមគាត់មិនត្រូវការព្រះពុទ្ធសាសនា សូម្បីព្រះវិហារនៅ

ស្រុកខ្ញុំនោះសាងសង់ពីស៊ីម៉ង់ស្រុតិស្ទ សរសរមួយៗអោបពីរនាក់មិនជុំទេ វាយបំបែកខ្ទិចរុះរើធ្វើកន្លែងមន្ទីរពេទ្យវះកាត់ ឥឡូវជិតសាងសងបានវិញហើយតែតូចៗ

វណ្ណៈ៖ ចឹងបើសិនជាសម័យខ្មែរក្រហមមានវត្តឲ្យប្រជាជនគោរពប្រហែលជាមិនសូវមានអំពើហឹង្សាចឹងទេ?

សឿត៖ បាទ! បើគេឲ្យយើងគោរពចុះមានអី តែគេមិនជឿពីព្រះពុទ្ធពីសាសនា គេមិនជឿផងៗ

វណ្ណៈ៖ ចឹងមិនជឿមានមនុស្សស្លាប់ច្រើន?

សឿត៖ បាទ! ចឹងប្រជាជនពលរដ្ឋគ្មានអីធ្វើ បើនិយាយពីសាសនាកើតដោយសាររដ្ឋគ្រប់គ្រងបើរដ្ឋមិនគ្រប់គ្រងហើយធ្វើយ៉ាងម៉េចទៅរួចៗ

វណ្ណៈ៖ ចឹងជុំវិញបញ្ហាអ្នកជិតខាងឥឡូវ តើការរាប់អានយ៉ាងម៉េចហើយជំនាន់តស៊ូយើងរាប់អានយ៉ាងម៉េច មានភាពខុសគ្នាដែលឬយ៉ាងម៉េច ការរាប់អានអ្នកជិតខាង?

សឿត៖ សព្វថ្ងៃនេះខ្ញុំឃើញខ្ញុំនិយាយត្រង់ ជំនាន់យើងនៅកំពង់ប្រយុទ្ធគ្នាជាមួយរដ្ឋាភិបាលដូចថាការសាមគ្គីគ្នា ខ្លាំងជាងសព្វថ្ងៃ សព្វថ្ងៃដោយសារអីគេអាងថាច្រើនប្រើលុយ ជំនាន់នោះសូម្បីកាប់មាន់មួយ កាប់ចែកគ្នាឲ្យផ្ទះនេះមួយដុំផ្ទះនោះមួយដុំ តែសព្វថ្ងៃដូចថាវាមិនខុសគ្នាប៉ុន្មានទេ គ្រាន់ថាគេប្រើលុយពេញដៃ ចឹងគេចង់គិតកំរៃរបស់គេៗ

វណ្ណៈ៖ ចឹងខ្ញុំចង់សួរទៀតរាល់ថ្ងៃហ្នឹង បើសិនជាមានជនជាតិផ្សេងគេមករស់នៅជិតយើងដែរ ពូសប្បាយចិត្តទេ បើសិនជាអ្នកផ្សេង សំដៅលើជនជាតិផ្សេង មិនមែនជាជនជាតិខ្មែរមកនៅជិតយើងដែរ យើងសប្បាយចិត្តដែលអត់?

សឿត៖ ជនបរទេសៗ

វណ្ណៈ៖ ដូចជាយួន-ថៃអីហ្នឹងចឹង យើងសប្បាយចិត្តទេ?

សឿត៖ អត់ទេៗ

វណ្ណៈ៖ ចឹងបើខ្មែរដូចគ្នា?

សឿត៖ ខ្មែរដូចគ្នាទោះបីឥសាន អីណាណី ខេត្តណាក៏ដោយឲ្យតែខ្មែរយើង បើបរទេសគេមកនៅជាមួយយើងមិនស្រួលទេ គេអាចមានមហិចតាផ្សេងយើងមិនដឹងគេដែរ ចឹងយើងមិនគួរទេ បើថាគេមករកស៊ីយើងមិនដឹងណា មកជំនួញអីៗ

វណ្ណៈ៖ អាហ្នឹងមិនអីទេ?

សឿត៖ បាទៗ

វណ្ណៈ៖ ចឹងបោះទីតាំងនៅរឿងផ្សេង?

សឿត៖ បោះទីតាំងនៅវាពិបាកនិយាយដែលអាហ្នឹង យូរៗទៅគេពង្រីកគេពង្រឹងអីៗ

វណ្ណៈ៖ ចឹងរាល់ថ្ងៃហ្នឹងនៅក្នុងស្រុកភូមិមានគណៈបក្សនយោបាយប៉ុន្មានដែលរាល់ថ្ងៃហ្នឹង?

សឿត៖ ខ្ញុំមិនសូវដឹងទេសព្វថ្ងៃ ខ្ញុំដឹងថាសមរង្ស៊ីមួយក្រៅពីហ្នឹងមិនដឹងទេ។

វណ្ណៈ៖ ចឹងអាចមានគណៈបក្សសមរង្ស៊ីនិងគណៈបក្សប្រជាជនតែពីរហ្នឹងទេ?

សឿត៖ បាទ។

វណ្ណៈ៖ ចឹងអត់មានលើកផ្លាកគណៈបក្សអីផ្សេងទៀតទេ?

សឿត៖ អត់ទេ។

វណ្ណៈ៖ បើនៅក្នុងភ្នំអីគេមានគណៈបក្សច្រើន?

សឿត៖ បាទ! នៅនេះខ្ញុំមើលប៉ាយគេឃើញតែគណៈបក្សសង្គ្រោះជាតិនិងគណៈបក្សប្រជាជនហ្នឹង អត់មានឃើញអីទៀត។

វណ្ណៈ៖ ចឹងដូចជាអ្នកភូមិដូចគ្នាខ្លះកាន់ខាងគណៈបក្សប្រជាជនខ្លះកាន់ខាងគណៈបក្សសមរង្ស៊ី តើប្រជាជនដូចគ្នាដែលលើកប៉ាយតាមមុខផ្ទះហ្នឹង ពួកគាត់ហ្នឹងអាចនិយាយរកគ្នាត្រូវគ្នាជួបគ្នាបុកយ៉ាងម៉េចដែរ?

សឿត៖ បើនិយាយពីស្រុកនេះវិញខ្ញុំឃើញ គណៈបក្សសមរង្ស៊ីជាមួយគណៈបក្សប្រជាជនដល់ពេលជួបគ្នាផឹកស៊ីហូបចុកធម្មតាទេ ធ្វើស្រែចម្ការជាមួយគ្នាធម្មតា។

វណ្ណៈ៖ អត់មានទាស់គ្នាទេ?

សឿត៖ អត់មានទាស់អីទេ ប៉ុន្តែសួរថា ហេតុអីបានជាឯងទៅនោះវិញ បងខ្ញុំខឹងជាមួយបងនេះបងនោះ ចឹងបុគ្គលខឹងបុគ្គលណាស់ ឧទាហរណ៍ពីមុនទេតាមខ្ញុំដឹង ពីអាណត្តិខ្ញុំនៅក្រុមប្រឹក្សាអាណត្តិមួយ ខឹងជាមួយមេភូមិ មេភូមិនោះវាឡូឡាជេរគេឯងហើយមិនដឹងក្បាលដឹងកន្ទុយភូមិត្រាំបោង បងសួរខ្ញុំ ខ្ញុំសុំទៅចូលគណៈបក្សសមរង្ស៊ី ឯងមកសុំអីអញជាសិទ្ធរបស់ឯងឯងធ្វើអីធ្វើទៅ អញអត់ដឹងទេ ចឹងឯងខឹងអី ខ្ញុំអត់មានទាស់ជាមួយគណៈបក្សទេ តែខ្ញុំស្អប់បុគ្គល។

វណ្ណៈ៖ ចឹងជាសិទ្ធរបស់គាត់?

សឿត៖ បាទ! គាត់ថា ឯងគិតមើលសិនអាអូន ឯងខឹងបុគ្គលឯងម៉ែទាំងអស់ បងខ្ញុំសាកមើលឲ្យវាដឹងខ្លួន ដល់ក្រោយមកវាទៅម៉ាខ្យល់វា បានខ្ញុំមកវិញ គាត់ថាមកវិញមកទៅអញមានថាអីឯងមកវិញខ្ញុំមិនដេញឯង មកវិញក៏ខ្ញុំមិនថាបើឯងថាមកទៅ។

វណ្ណៈ៖ បាទ។

សឿត៖ ខ្ញុំទាក់ទាញបានច្រើនដែលសព្វថ្ងៃ ខ្ញុំធ្វើបាន១០ឆ្នាំដែរ។

វណ្ណៈ៖ ចឹងពូមានប្រាក់ខមត្តម្ពសម្រាប់អាត្រែតដែលរាល់ថ្ងៃហ្នឹង?

សឿត៖ អត់មានទេ ។

វណ្ណៈ៖ ចឹងហេតុអីក៏អត់មានពូ តាមមើលពូធ្លាប់តស៊ូអីចឹង នៅកន្លែងខ្លះផ្លូវឃើញដាក់ពាក្យតវ៉ាអីចឹងដែរ ពូអាចស៊ើបសួរគេ ពូស្គាល់តាសារី សយ?

សឿត៖ សារី សយ ហ្នឹងតែខ្ញុំបានមកហើយតែមិនទាន់ធ្លាក់មកទេ ។

វណ្ណៈ៖ ចឹង?

សឿត៖ បើនិយាយពីក្រុមប្រឹក្សាផុតអាណត្តិហើយទេ ដូចជាមិនមានប្រាក់អាត្រែតទេតាមមើល អត់មានទេ តែខ្ញុំនេះសំណាំងល្អបានមេភូមិគាត់ជួយខ្ញុំដែរ គាត់នឹកអាណិតខ្ញុំ គាត់ធ្លាប់រាប់អានធ្លាប់គោរពខ្ញុំដែរ គេឲ្យខ្ញុំទៅសួរបង សយ មើលខ្ញុំក៏ទៅសួរ គេមើលកិនភាគគេមើលស្នាកស្នាមអី សួរពីអាយុកាលដែលខ្ញុំលះបង់ គេសួរខ្ញុំ ខ្ញុំប្រាប់គេថាខ្ញុំចូលតាំងពី៧៣ដែរ បើប៉ុននេះអាចបាន ខ្ញុំអត់ទាន់ទុកចិត្តដែរ ដល់ក្រោយមកខាងក្រសួងចុះមកត្រួតពិនិត្យបាន បាត់យូរពេកដូចជាគ្មានសង្ឃឹមទេ ហើយប៉ុន្មានថ្ងៃនេះគេប្រាប់មកទៀតថាកុំទៅណាឆ្ងាយ លុយជិតធ្លាក់មកហើយ ។

វណ្ណៈ៖ បាទ!ចឹងប្រហែលជាគេគិតគូរដែរ ព្រោះធ្លាប់បម្រើការងាររមន្ត្រីរាជការដែរ?

សឿត៖ បាទ!ខ្ញុំស្តាប់វិទ្យុផ្សាយគួរមានសង្ឃឹមមែន មន្ត្រីរាជការអតីតមែនទេ ខ្ញុំស្តាប់វិទ្យុផ្សាយដូចមានសង្ឃឹមដែរ ។

វណ្ណៈ៖ បានចឹងល្អគ្រាន់ដល់ខែបានលុយខ្លះទៅគ្រាន់ដឹកកាហ្វេនិងដោះស្រាយអីបានខ្លះ?

សឿត៖ ហ្នឹងហើយ ។

វណ្ណៈ៖ ចឹងនៅក្នុងភូមិហ្នឹងមិនទាន់មានក្រុមហ៊ុនណាមកបង្កើតរោងចក្រអីទេ?

សឿត៖ អត់មានទេ ។

វណ្ណៈ៖ ចឹងបើសិនជាមានរោងចក្រអីកូនចៅនិងអ្នកភូមិអាចមានជីវភាពធូរធារមួយកំរិតទៀតទេ?

សឿត៖ បើសិនជាមានរោងចក្រអីកូនចៅកាន់តែធូរមួយកំរិតទៀតហើយ មិនពិបាកទៅធ្វើការនៅណាឆ្ងាយ ។

វណ្ណៈ៖ ចឹងនៅក្នុងភូមិហ្នឹងកូនចៅអ្នកស្រុកភូមិមានទៅធ្វើការនៅប្រទេសថៃច្រើនទេឬមិនសូវទេ?

សឿត៖ បើនិយាយពីឃុំមានដែរ តែសូវទៅច្រើនប៉ុន្មានទេ ធ្វើការនៅស្រុកយើងនៅភ្នំពេញទៅថៃនោះក៏មិនជាច្រើនអីប៉ុន្មានដែរ ភាគច្រើនអ្នកស្រុកនេះច្រើនតែបន្ទាចកូនថា ប្រយ័ត្នចាញ់បោកគេអីណា តែម៉ែឪខ្លះថាមិនដែលទេ ឃើញគេទៅបានមែន ទៅហ្នឹងគេទៅ ភាគច្រើននៅខ្លាចមិនទាន់ទុកចិត្តទេ ខ្លាចលោមេខ្យល់គេបោកប្រាស់អីយកកូនទៅណាណី បើសិនមានរោងចក្រនៅក្នុងភូមិក្នុងស្រុកទៀត កាន់តែមហាអស្ចារ្យ ។

វណ្ណៈ៖ សង្ឃឹមថាថ្ងៃក្រោយប្រទេសជាតិរីកចំរើនទៅអាចមាន?

សឿតៈ បាទ ។

វណ្ណៈ៖ ចឹងបើនិយាយអំពីទំនៀមទំលាប់ព្រះពុទ្ធសាសនាប្រពៃណីស្លៀកពាក់វិញ ដូចថាសម័យឥឡូវយើងស្លៀកពាក់បែបយ៉ាងម៉េចហើយកាលសម័យបីឆ្នាំមានការស្លៀកពាក់ល្អដែរអត់ តាមរបៀបបុរាណដែលអត់ សម័យមុនស្លៀកពាក់បែបយ៉ាងម៉េចពូប្រៀបធៀបបីជំនាន់មើលកាលសម័យសម្ដេចសីហនុការស្លៀកពាក់យើងមានហូប្រមូងតាមប្រពៃណីឬយ៉ាងម៉េចដែលកាលហ្នឹង?

សឿតៈ កាលជំនាន់សម្ដេចតាយើងនោះ នៅបុរាណច្រើនដែរ ការស្លៀកពាក់ខ្ញុំឃើញ ការកូនចៅខ្លះឃើញស្លៀកចង់ក្បិននោះ ហើយអត់មានអាវទេ ពាក់តែស្បៃក៏មានដែរ ខ្លះឃើញស្លៀកខោអាវវែងដូចយើងសព្វថ្ងៃធម្មតាគេនិយម ហើយមានសម័យមួយគេហៅថា ចាស់ៗថាសម័យខោជើងប៉ាត់នោះ ជំនាន់សម្ដេចតាយើងមានខ្ញុំឃើញ ហើយស្រីៗស្លៀកជើងអូសដីហើយខោរីបក្ដោប ហើយសម័យយើងនេះអត់មានអាហ្នឹង ស្លៀកបំពាក់ទោះបីគេយ៉ាងម៉េចវាម៉្យាងរបស់គេ ។

វណ្ណៈ៖ ចឹងតាមសម័យកាល?

សឿតៈ បាទ!តាមសម័យកាល ។

វណ្ណៈ៖ លើកលែងតែសម័យខ្មែរក្រហម?

សឿតៈ សម័យខ្មែរក្រហមហ្នឹងខ្អែកសុទ្ធហើយ ។

វណ្ណៈ៖ ចឹងមកដល់ឥឡូវក្មេងៗស្លៀកពាក់យ៉ាងម៉េចដែរ ក្លាយពីមុនដែលឬវាទំនើបយ៉ាងម៉េចទៀតពូ?

សឿតៈ ក្មេងសព្វថ្ងៃវាទំនើបទៅតាមធន់ធានរបស់គ្រួសារនីមួយៗ ចង់ស្លៀកពណ៌ណាក៏បាន ម៉ូតណាក៏បាន ។

វណ្ណៈ៖ ចឹងរាល់ថ្ងៃនេះបើសិនជាយើងមានរឿងអី យើងអាចពឹងពាក់ទៅលើប្រព័ន្ធផ្លូវច្បាប់បានទេថាច្បាប់ហ្នឹងល្អឬមិនទាន់ល្អនេះបើតាមទស្សនៈរបស់ពូគិត?

សឿតៈ ទេ បើតាមខ្ញុំយល់បង្កើតច្បាប់ហើយខ្ញុំទុកចិត្តច្បាប់ហ្នឹងហើយ ព្រោះច្បាប់បង្កើតសម្រាប់ប្រជាពលរដ្ឋគោរពតើ បើយើងមានបញ្ហាអីប្ដឹងច្បាប់ ចុះច្បាប់ដោះស្រាយតាមយុត្តិធម៌ខ្ញុំជឿចឹងចិត្តខ្ញុំវិញ ។

វណ្ណៈ៖ បាទ!ចឹងខ្ញុំដូចជាអស់សំនួរសួរពូហើយ តើពូមានសំនួរចង់បន្ថែមនិយាយដែលខ្ញុំមិនបានសួរនាំពូ មានចំណុចណាដែលពូចង់សួរ មានចំណុចណាដែលពូចង់និយាយទៀតទេ ។

សឿតៈ ខ្ញុំដូចជាអស់ដែលហើយខ្ញុំមិនមែនជាអ្នកចេះនិយាយទេ សួរខ្ញុំ ខ្ញុំចេះតែឆ្លើយ ។

វណ្ណៈ៖ តាមពិតពូនិយាយបានក្បោះក្បាយល្អណាស់ ។

សឿតៈ បាទ!ឲ្យខ្ញុំនិយាយខ្លួនខ្ញុំ ខ្ញុំអត់និយាយកើតដែលហ្នឹង បើសួរខ្ញុំចេះតែឆ្លើយ ។

វណ្ណៈ៖ ចឹងខ្ញុំអរគុណច្រើនពូ ។

សឿតៈ បាទ ។

**ចប់**